ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៤៤ ព.ណ.ន.ចបព ប្រក

# ប្រកាស
# ស្តីពី
# ការធ្វើសាមញ្ញកម្មនៃការចារចុះបញ្ជីពាណិជ្ជកម្ម ដំណាក់កាលទី២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២២/០០២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២២/០០៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

## សម្រេច

**ប្រការ១ _ គោលបំណង**

ប្រកាសនេះមានគោលបំណងបន្តការធ្វើសាមញ្ញកម្ម និងទំនើបកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលើប្រកាសលេខ១១៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម។

**ប្រការ២ _ ពាក្យសម្គាល់ទម្រង់នៃសហគ្រាសពាណិជ្ជកម្ម**

ពាក្យសម្គាល់ទម្រង់នៃសហគ្រាសពាណិជ្ជកម្មដូចខាងក្រោមត្រូវសរសេរនៅពីលើ ឬពីមុខនាមករណ៍ដើម៖

- សហគ្រាសឯកបុគ្គល ត្រូវដាក់នូវពាក្យថា "សហគ្រាសឯកបុគ្គល"
- សាខាក្រុមហ៊ុនក្នុងស្រុក ត្រូវដាក់នូវពាក្យថា "សាខាក្រុមហ៊ុនក្នុងស្រុក"
- សាខាក្រុមហ៊ុនបរទេស ត្រូវដាក់នូវពាក្យថា "សាខាក្រុមហ៊ុនបរទេស"
- ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ត្រូវដាក់ពាក្យថា "ការិយាល័យតំណាងពាណិជ្ជកម្មបរទេស ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម"។

ពាក្យសម្គាល់ទម្រង់នៃសហគ្រាសពាណិជ្ជកម្មដូចខាងក្រោមត្រូវសរសេរនៅខាងចុង ឬខាងក្រោមនាមករណ៍ដើម៖

- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" ឬអក្សរកាត់ថា "ស.ទ"
- ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ឬអក្សរកាត់ថា "ស.ក"
- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬអក្សរកាត់ថា "ឯ.ក"
- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ឬអក្សរកាត់ថា "ម.ក" ។

ការជ្រើសរើសនាមករណ៍សហគ្រាសពាណិជ្ជកម្ម ជាសិទ្ធិរបស់អ្នកស្នើសុំចុះបញ្ជី លើកលែងតែនាមករណ៍ដែលហាមឃាត់ដោយច្បាប់ ឬតម្រូវឱ្យមានការស្នើសុំគោលការណ៍ជាមុនពីរាជរដ្ឋាភិបាល ឬនាមករណ៍ដែលបានចុះបញ្ជីជានីតិបុគ្គលស្របច្បាប់រួចហើយ។

**ប្រការ៣ _ កម្មវត្ថុអាជីវកម្ម**

អ្នកស្នើសុំអាចជ្រើសរើសកម្មវត្ថុអាជីវកម្មដោយសេរី និងស្របតាមបទប្បញ្ញត្តិជាធរមាន វៀរលែងតែកម្មវត្ថុអាជីវកម្មដូចចែងក្នុងឧបសម្ព័ន្ធទី១ ដែលតម្រូវឱ្យមានការស្នើសុំជាមុនពីស្ថាប័នមានសមត្ថកិច្ច។

**ប្រការ៤ _ លក្ខន្តិកៈក្រុមហ៊ុន**

រាល់ការចុះបញ្ជីពាណិជ្ជកម្ម ត្រូវធ្វើតាមរយៈគេហទំព័រ www.registrationservices.gov.kh ។

អ្នកស្នើសុំមានសិទ្ធិជ្រើសរើសគំរូលក្ខន្តិកៈដូចចែងក្នុងឧបសម្ព័ន្ធទី២។ ក្នុងគោលដៅធានាសាមញ្ញកម្មនៃឯកសារតម្រូវ រាល់ការកែប្រែព័ត៌មានក្រុមហ៊ុន ត្រូវធ្វើតែនៅទំព័រចុងក្រោយនៃលក្ខន្តិកៈដែលបានភ្ជាប់ជូន។

ការតម្កល់លក្ខន្តិកៈក្រុមហ៊ុន ឬឯកសារពាក់ព័ន្ធ មិនតម្រូវឱ្យមកតម្កល់ដោយផ្ទាល់នៅក្រសួងពាណិជ្ជកម្មទៀតទេ។ ក្រសួងពាណិជ្ជកម្ម នឹងបញ្ជាក់សច្ចភាពនៃការតម្កល់លក្ខន្តិកៈក្រុមហ៊ុន តាមរយៈ verify.gov.kh ជំនួសការប្រើប្រាស់ត្រាបញ្ជាក់ការតម្កល់លក្ខន្តិកៈវិញ។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រទឹងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ប្រការ៥ _ ការចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**

រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលបានចុះបញ្ជីបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា អាចបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកមួយ ឬច្រើនបាន។

ក្រុមហ៊ុនដែលបង្កើតសាខា ត្រូវហៅថា "ក្រុមហ៊ុនដើម"។ ក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើសកម្មភាព និងកាតព្វកិច្ចរបស់សាខាក្រុមហ៊ុនក្នុងស្រុក។

សំណុំឯកសារចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក ត្រូវបញ្ចូលជាទម្រង់អេឡិចត្រូនិកតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចខាងក្រោម៖

១. ពាក្យស្នើសុំ (១ ច្បាប់)

២. លិខិតប្រគល់សិទ្ធិ (១ ច្បាប់)

៣. ឯកសារបញ្ជាក់អាសយដ្ឋានទីស្នាក់ការចុះបញ្ជីសាខា (១ ច្បាប់)

៤. នាយកសាខា (១ ច្បាប់)

- អត្តសញ្ញាណប័ណ្ណ (សញ្ជាតិខ្មែរ) ឬលិខិតឆ្លងដែន (សញ្ជាតិបរទេស)
- រូបថត ៤X៦ ផ្ទៃខាងក្រោយពណ៌ស មិនលើសពីរយៈពេល ៦ (ប្រាំមួយ) ខែ

៥. ឯកសារយោងពីក្រសួង-ស្ថាប័នពាក់ព័ន្ធ (១ ច្បាប់ ប្រសិនបើមាន)។

អភិបាល ១ (មួយ) រូប មានសិទ្ធិចុះហត្ថលេខាលើសំណើស្នើសុំ និងលិខិតប្រគល់សិទ្ធិ សម្រាប់ចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុកបាន។

រាល់ការផ្លាស់ប្តូរនាយកសាខាក្រុមហ៊ុនក្នុងស្រុក មិនតម្រូវឱ្យមានការជូនដំណឹងមកក្រសួងពាណិជ្ជកម្មទេ។

**ប្រការ៦ _ ការតម្កល់ព័ត៌មានលេខាធិការក្រុមហ៊ុន**

លេខាធិការក្រុមហ៊ុន សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងដោយក្រុមហ៊ុនមូលធន ហើយមានសិទ្ធិក្នុងការទទួល និងរក្សាទុកឯកសារដែលពាក់ព័ន្ធដល់កិច្ចការរបស់ក្រុមហ៊ុន។ លេខាធិការក្រុមហ៊ុនមានតួនាទីភារកិច្ចស្របតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០២២។

ក្រុមហ៊ុនមូលធនត្រូវចាត់តាំងលេខាធិការក្រុមហ៊ុនម្នាក់ ឬច្រើននាក់ តាមការចាំបាច់របស់ខ្លួន។

បុគ្គលគ្រប់រូប អាចត្រូវបានជ្រើសតាំងជាលេខាធិការក្រុមហ៊ុន លើកលែងតែបុគ្គលដែលមានវិសមិតភាពមុខងារ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។

ការតម្កល់ព័ត៌មានលេខាធិការក្រុមហ៊ុន ត្រូវធ្វើតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងដោយឥតគិតថ្លៃ។ ក្រុមហ៊ុនមូលធនត្រូវផ្តល់ព័ត៌មានលេខាធិការក្រុមហ៊ុនរបស់ខ្លួន ដូចខាងក្រោម៖

១. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន

២. ទីលំនៅបច្ចុប្បន្ននៅព្រះរាជាណាចក្រកម្ពុជា

៣. លេខទូរសព្ទទំនាក់ទំនង និងអ៊ីម៉ែល។

លក្ខខណ្ឌដើម្បីប្រកបវិជ្ជាជីវៈជាលេខាធិការក្រុមហ៊ុន មិនតម្រូវឱ្យមានការតម្កល់ប្រាក់ក្នុងការបំពេញមុខងារឡើយ។

**ប្រការ៧ _ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**

រាល់ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ទាក់ទងទៅនឹងស្ថានភាពក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំត្រូវធ្វើតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមរយៈគេហទំព័រ www.registrationservices.gov.kh និងធ្វើការបង់ប្រាក់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដោយផ្ទាល់ទៅតាមសេវាអេឡិចត្រូនិកធនាគារ។

ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំអាចធ្វើទៅបានក្នុងរយៈពេលមុន ៣ ខែនៃថ្ងៃខួបកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងផ្តល់រយៈពេលអនុគ្រោះ ១៥ ថ្ងៃបន្ទាប់ពីថ្ងៃខួបកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម។

**ប្រការ៨ _ ការផ្តល់ជូនគណនី username និង password ដើម្បីគ្រប់គ្រងព័ត៌មានក្រុមហ៊ុន**

ក្រុមការងារចំពោះកិច្ចសម្រាប់ដោះស្រាយសំណូមពររបស់វិស័យឯកជនលើការងារចុះបញ្ជីពាណិជ្ជកម្ម មានសមត្ថកិច្ចសម្រួលដល់ក្រុមហ៊ុនដែលបានចុះបញ្ជីរួចរាល់ ក្នុងការស្នើសុំការធ្វើបច្ចុប្បន្នភាពការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ តាមប្រព័ន្ធព័ត៌មានវិទ្យា និងផ្តល់គណនី username និង password ដែលបានបាត់បង់ ឬមិនទាន់បានធ្វើបច្ចុប្បន្នភាពត្រឹមត្រូវតាមកាលកំណត់ សម្រាប់ចូលទៅប្រើប្រាស់ និងគ្រប់គ្រងគណនីព័ត៌មានក្រុមហ៊ុនដែលមានស្រាប់។

បុគ្គលដែលអាចស្នើសុំគណនី username និង password ត្រូវជាលេខាធិការក្រុមហ៊ុន ឬបុគ្គលដែលបានទទួលសិទ្ធិជាតំណាងក្រុមហ៊ុន (មិនចាំបាច់មានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការប្រគល់សិទ្ធិ លិខិតប្រគល់សិទ្ធិអាចចេញដោយប្រធានក្រុមប្រឹក្សាភិបាល ឬនាយកប្រតិបត្តិ)។

ការស្នើសុំគណនី username និង password ដោយបុគ្គលដែលបានទទួលសិទ្ធិជាតំណាងក្រុមហ៊ុន អាចទំនាក់ទំនងមកកាន់ប្រព័ន្ធទំនាក់ទំនងសាធារណៈក្រសួងពាណិជ្ជកម្ម ១២៦៦ (សូមចុចលេខ២ សម្រាប់ព័ត៌មានលម្អិតលើការងារចុះបញ្ជីពាណិជ្ជកម្ម និងការងារពាក់ព័ន្ធនឹងកិច្ចសម្រួលនេះ)។

**ប្រការ៩ _ ការរំលាយ និងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម**

សំណុំឯកសារស្តីពីសំណើសុំប្រកាសពីបំណងក្នុងការជម្រះបញ្ជី ឬរំលាយក្រុមហ៊ុន សហគ្រាស មានដូចខាងក្រោម៖

១. សេចក្តីប្រកាសពីបំណងរំលាយ ចំនួន (១ ច្បាប់)

២. សេចក្តីសម្រេចសមូហភាពរបស់ម្ចាស់ហ៊ុន ចំនួន (១ ច្បាប់)។

ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយជាទម្រង់អេឡិចត្រូនិកស្របតាមមាត្រា២៥៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

សំណុំឯកសារចុះបញ្ជីលើការរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោម៖

១. ពាក្យស្នើសុំ ចំនួន (១ ច្បាប់)

២. លិខិតបញ្ជាក់ស្ថានភាពសារពើពន្ធរបស់ក្រុមហ៊ុន ចំនួន (១ ច្បាប់)

៣. របាយការណ៍ស្តីពីការជម្រះបញ្ជី រំលាយក្រុមហ៊ុន ចំនួន (១ ច្បាប់)

៤. វិក្កយបត្របង់ពន្ធបន្ថែម (ប្រសិនបើមានការពិន័យនៅចំណុចទី៤) ចំនួន (១ ច្បាប់)

៥. របាយការណ៍បិទបញ្ជីប្រចាំឆ្នាំ (ឆ្នាំចុងក្រោយ) ចំនួន (១ ច្បាប់)

៦. លិខិតតែងតាំងអ្នកជម្រះបញ្ជី ចំនួន (១ ច្បាប់)។

ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាលត្រូវធានាអះអាងចំពោះរាល់ព័ត៌មាន សម្រាប់ការស្នើសុំរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ឯកសារតម្រូវដែលខ្លួនបានបំពេញ និងបញ្ចូលតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាទម្រង់អេឡិចត្រូនិក រួមបញ្ចូលទាំងហត្ថលេខាឌីជីថល ដែលអនុលោមស្របតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើមាន) ថាពិតជាព័ត៌មាន ឯកសារត្រឹមត្រូវ និងមិនក្លែងបន្លំ។

គំរូសេចក្តីប្រកាសពីបំណងរំលាយ និងពាក្យស្នើសុំ មានចែងក្នុងឧបសម្ព័ន្ធទី៣។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រេងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

**ប្រការ១០ _ អវសានប្បញ្ញត្តិ**

ជំពូកទី១០ នៃប្រកាសលេខ១១៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការធ្វើការសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម ត្រូវទុកជានិរាករណ៍។

ប្រកាសនេះត្រូវអនុវត្តស្របគ្នាជាមួយប្រកាសលេខ១១៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម លើកលែងតែបញ្ញត្តិណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ _**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធានគ្រប់នាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងប្រធានគ្រប់អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព។

ថ្ងៃ អង្គារ ១០កើត ខែ ផល្គុន ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ព្រះរាជាណាចក្រកម្ពុជា ក្រសួងពាណិជ្ជកម្ម

**ចម និម្មល**

**កន្លែងទទួល៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ១១ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh

**ឧបសម្ព័ន្ធទី១៖** តារាងរាយនាមប្រភេទអាជីវកម្មដែលចាំបាច់ត្រូវស្នើសុំគោលការណ៍ជាមុនពីក្រសួង/ស្ថាប័ន
ភ្ជាប់នឹងប្រកាសលេខ ០៤៤ ពណ.សាន.សបព ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៦
ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម ដំណាក់កាលទី២

| តារាងរាយនាមប្រភេទអាជីវកម្មដែលចាំបាច់ត្រូវស្នើសុំគោលការណ៍ជាមុនពីក្រសួង/ស្ថាប័ន | | |
|---|---|---|
| **វិស័យទូរគមនាគមន៍** | | |
| **ក្រសួង/ស្ថាប័ន** | **ប្រភេទអាជីវកម្ម** | **យោង** |
| ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រតិបត្តិការទូរគមនាគមន៍ | ប្រកាសលេខ ១២២ បទ.ប្រក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍ |

| វិស័យទេសចរណ៍ | | |
|---|---|---|
| **ក្រសួង/ស្ថាប័ន** | **ប្រភេទអាជីវកម្ម** | **យោង** |
| ក្រសួងទេសចរណ៍ | ការីទេសចរណ៍ ភ្នាក់ងារទេសចរណ៍ និងសាខា | ប្រកាសលេខ ១១៣ ប្រក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់ការីទេសចរណ៍ ភ្នាក់ងារទេសចរណ៍ និងសាខា |
| | បៀរហ្គាឌិន | ប្រកាសលេខ ១៧៥ ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មបៀរហ្គាឌិន |
| | ភោជនីយដ្ឋាន និងអាហារដ្ឋាន | ប្រកាសលេខ ០៧៦ ប្រក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មភោជនីយដ្ឋាន និងអាហារដ្ឋាន |

| វិស័យល្បែងពាណិជ្ជកម្ម | | |
|---|---|---|
| ក្រសួង/ស្ថាប័ន | ប្រភេទអាជីវកម្ម | យោង |
| គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា | កាស៊ីណូ និងល្បែងផ្សងសំណាង | ប្រកាសលេខ ០០២ គ.ល.ក.ប្រក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់ ការផ្ទេរ និងការបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ និងអាជ្ញាបណ្ណល្បែងផ្សងសំណាង |
| | បុគ្គលិកពិសេសកាស៊ីណូ | ប្រកាសលេខ ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទនិងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ |
| | | ប្រកាសលេខ ០០៤ គ.ល.ក.ប្រក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ៦ នៃប្រកាសលេខ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ |

| វិស័យធនាគារ | | |
|---|---|---|
| ក្រសួង/ស្ថាប័ន | ប្រភេទអាជីវកម្ម | យោង |
| ធនាគារជាតិនៃកម្ពុជា | ធនាគារពាណិជ្ជ | ប្រកាសលេខ ធ៧-០០-០៤ ប្រ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះធនាគារពាណិជ្ជ |
| | មីក្រូហិរញ្ញវត្ថុ | ប្រកាសលេខ ធ៧-០០-០៦ ប្រ.ក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| | នាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ | ប្រកាសលេខ ធ៩.០២១.០៥២.ប្រ.ក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មនាំចេញ-នាំចូល លោហធាតុ និងត្បូងថ្មមានតម្លៃ |

| វិស័យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | | |
|---|---|---|
| **ក្រសួង/ស្ថាប័ន** | **ប្រភេទអាជីវកម្ម** | **យោង** |
| និយ័តករមូលបត្រកម្ពុជា | មូលបត្រ | ប្រកាសលេខ ០០១/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ |
| | ឧបករណ៍និស្សន្ទ | ប្រកាសលេខ ០០៥/២០ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ស្តីពីវិសោធនកម្មលើប្រកាសលេខ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ |
| | គម្រោងវិនិយោគរួម | ប្រកាសលេខ ០០៣/១៨ គ.ម.ក./ប្រ.ក. ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម |
| និយ័តករបរធនបាលកិច្ច | បរធនបាល | ប្រកាសលេខ ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីវិធានការក្នុងការគ្រប់គ្រងការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច |
| និយ័តករធានារ៉ាប់រងកម្ពុជា | ធានារ៉ាប់រង | ប្រកាសលេខ ០២៤ អ.ស.ហ.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រង |
| | ធានារ៉ាប់រងខ្នាតតូច | ប្រកាសលេខ ២០២ សហវ.ប្រក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២១ ស្តីពីការផ្តល់អាជ្ញាបណ្ណធានារ៉ាប់រងខ្នាតតូច |
| | សេវាគាំទ្រអាជីវកម្មធានារ៉ាប់រង | ប្រកាសលេខ ០៦០ អ.ស.ហ.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង |
| | អន្តរការីធានារ៉ាប់រង | ប្រកាសលេខ ០៥៩ អ.ស.ហ.ប្រក ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង |

| វិស័យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | | |
|---|---|---|
| ក្រសួង/ស្ថាប័ន | ប្រភេទអាជីវកម្ម | យោង |
| និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ | បញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន | ប្រកាសលេខ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន |
| | អភិវឌ្ឍអចលនវត្ថុ | ប្រកាសលេខ ០៤៧ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មអភិវឌ្ឍអចលនវត្ថុ |
| និយ័តករគណនេយ្យ និងសវនកម្ម | វិជ្ជាជីវៈគណនេយ្យ និងសវនកម្ម | ប្រកាសលេខ ០១៩ អ.ស.ហ. ប្រក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម |

| វិស័យសេវាសន្តិសុខឯកជន | | |
|---|---|---|
| ក្រសួង/ស្ថាប័ន | ប្រភេទអាជីវកម្ម | យោង |
| ក្រសួងមហាផ្ទៃ | សកម្មភាពរក្សាសន្តិសុខឯកជន | អនុក្រឹត្យលេខ ២៨៩ អនក្រ.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងសន្តិសុខឯកជន |

| វិស័យធនធានរ៉ែ | | |
|---|---|---|
| ក្រសួង/ស្ថាប័ន | ប្រភេទអាជីវកម្ម | យោង |
| ក្រសួងរ៉ែ និងថាមពល | រុករកធនធានរ៉ែ | អនុក្រឹត្យលេខ ៧២ អនក្រ.ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ |

**ឧបសម្ព័ន្ធទី២៖** គំរូលក្ខន្តិកៈក្រុមហ៊ុន

ភ្ជាប់នឹងប្រកាសលេខ ០៤៤ ពណ.អ.ចបព.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៦

ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម ដំណាក់កាលទី២

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម

# លក្ខន្តិកៈក្រុមហ៊ុន

# MEMORANDUM AND ARTICLES OF ASSOCIATION

## [ឈ្មោះ ក្រុមហ៊ុន]

## [COMPANY NAME]

គំរូលក្ខន្តិកៈ ផ្តល់ជូនដោយក្រសួងពាណិជ្ជកម្ម

សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

Single Member Private Limited Company

# លក្ខន្តិកៈក្រុមហ៊ុន

## ប្រការ ១

## ព័ត៌មានក្រុមហ៊ុន

ចាប់ពីថ្ងៃចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវបានចាត់ទុកថា មាននីតិបុគ្គលិកលក្ខណៈ និងជានីតិបុគ្គលដែលមានសិទ្ធិ ឈ្មោះ អាសយដ្ឋាន និងទ្រព្យសម្បត្តិផ្ទាល់របស់ក្រុមហ៊ុន។ ក្រុមហ៊ុននេះ ត្រូវគ្រប់គ្រង និងស្ថិតក្រោមច្បាប់ពាណិជ្ជកម្មដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងលក្ខន្តិកៈនេះ។ ក្រុមហ៊ុនត្រូវបន្តមាន រហូតដល់ការរំលាយក្រុមហ៊ុនត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ ការរំលាយក្រុមហ៊ុន ត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

ព័ត៌មានក្រុមហ៊ុនរួមមាន នាមករណ៍ ទ្រង់ទ្រាយ កម្មវត្ថុអាជីវកម្ម អាសយដ្ឋាន ដើមទុនចុះបញ្ជី តម្លៃចារឹកលើបណ្ណភាគហ៊ុន ព័ត៌មានម្ចាស់ហ៊ុន និងព័ត៌មានអភិបាល ត្រូវបានជូនភ្ជាប់ដូចក្នុងឧបសម្ព័ន្ធទី១ នៃលក្ខន្តិកៈក្រុមហ៊ុននេះ។ រាល់ការកែប្រែព័ត៌មានក្រុមហ៊ុនដូចជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

## ប្រការ ២

## ការបង្កើន និងបន្ថយដើមទុន

ដើមទុនរបស់ក្រុមហ៊ុន អាចត្រូវបានបង្កើនតាមសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។ ដើមទុនរបស់ក្រុមហ៊ុន អាចត្រូវបានបន្ថយបានតែមិនត្រូវឱ្យដើមទុននៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូង និងទាបជាងដើមទុនកំណត់ដោយច្បាប់ឡើយ។

## ប្រការ ៣

## ការផ្ទេរភាគហ៊ុន ក្នុងករណីមានមរណភាព ឬការរំលាយរបស់ម្ចាស់ភាគហ៊ុន

ក្នុងករណីម្ចាស់ភាគហ៊ុន ទទួលមរណភាព ឬ ត្រូវបានរំលាយ ភាគហ៊ុនទាំងអស់របស់ម្ចាស់ភាគហ៊ុន ត្រូវផ្ទេរទៅអ្នកដែលត្រូវទទួលមរតក ឬ បុគ្គលដែលទទួលបានប្រយោជន៍ ដែលមានសិទ្ធិបន្តប្រតិបត្តិការក្រុមហ៊ុនបន្តទៅទៀត។ បើមិនដូច្នោះទេ អ្នកដែលត្រូវទទួលមរតក ឬ បុគ្គលដែលទទួលបានប្រយោជន៍ អាចសុំរំលាយក្រុមហ៊ុននេះចោល ក្នុងករណីនេះទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ក្រោយពីបានទូទាត់កាត់សងតតិយជនដែលជាម្ចាស់បំណុលរបស់ក្រុមហ៊ុនហើយ ត្រូវបែងចែកទៅដល់អ្នកដែលត្រូវទទួលមរតក ឬ បុគ្គលដែលទទួលបានប្រយោជន៍តាមមរតកសាសន៍របស់ម្ចាស់ភាគហ៊ុន។

## ប្រការ ៤

## ការគ្រប់គ្រងក្រុមហ៊ុន

### ៤.១ ការតែងតាំងអភិបាល

(ក) ក្រុមហ៊ុនត្រូវដឹកនាំ និងគ្រប់គ្រងដោយម្ចាស់ភាគហ៊ុន ឬ ដោយអភិបាល។ ក្នុងករណីដែលក្រុមហ៊ុននេះត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអភិបាល ឬក្រុមប្រឹក្សាភិបាល អភិបាលទាំងនេះត្រូវទទួលបាន ប្រាក់បៀវត្ស ឬ ប្រាក់រង្វាន់ តាមការព្រមព្រៀងរវាងក្រុមហ៊ុន និងអភិបាល។

(ខ) អាណត្តិរបស់អភិបាលអាចមានរយៈពេលកំណត់ ឬមិនកំណត់។

(គ) អភិបាលអាចត្រូវបានជ្រើសតាំងឡើងវិញក្នុងករណីចាំបាច់ និងសមស្រប។

(ឃ) អភិបាលត្រូវ ជ្រើសតាំងតាមសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

(ង) អភិបាលអាចលាលែងពីតំណែងខ្លួនបាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនយ៉ាងតិចរយៈពេល ៣ (បី) ខែ អំពីការលាលែងនេះ តាមលិខិតប្រៃសណីយ៍ ទៅម្ចាស់ភាគហ៊ុន ដោយមានលិខិតបញ្ជាក់ពីការទទួលបានការជូនដំណឹងនោះផងដែរ ។

(ច) អភិបាលអាចត្រូវបានដកហូតពីតំណែងបាន ដោយសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

(ឆ) មុខតំណែងជាអភិបាល រង្វាន់ និងប្រាក់បៀវត្សរបស់អភិបាល ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

## ៤.២ ការជ្រើសតាំងប្រធានក្រុមប្រឹក្សាភិបាល

អភិបាលអាចជ្រើសតាំងប្រធានក្រុមប្រឹក្សាភិបាលពីក្នុងចំណោមសមាជិករបស់ខ្លួន និងកំណត់រយៈពេលដែល ប្រធានក្រុមប្រឹក្សាភិបាលនោះនឹងកាន់តំណែងរបស់ខ្លួន។ នៅក្នុងសន្និបាតនីមួយៗ ប្រសិនបើប្រធានក្រុមប្រឹក្សាភិបាលមិនមានវត្តមានក្នុងកំឡុងពេល ១០ (ដប់) នាទី បន្ទាប់ពីពេលវេលាកំណត់សម្រាប់បើកសន្និបាត អភិបាលដែលមានវត្តមានក្នុងសន្និបាតនោះ អាចជ្រើសរើសសមាជិកមួយរូបរបស់ពួកគេឱ្យធ្វើជាប្រធានក្រុមប្រឹក្សាភិបាលនៅក្នុងសន្និបាតនោះបាន។ ប្រធានក្រុមប្រឹក្សាភិបាលនឹងមិនមែនជាប្រធានក្រុមប្រឹក្សាភិបាលទៀតទេ ប្រសិនបើប្រធានក្រុមប្រឹក្សាភិបាលនោះលែងជាអភិបាលក្រុមហ៊ុន។

## ៤.៣ អំណាចរបស់អភិបាល ប្រធានក្រុមប្រឹក្សាភិបាល

### ៤.៣.១ អភិបាល

(ក) អភិបាលត្រូវមានសិទ្ធិអំណាចពេញលេញ ក្នុងការគ្រប់គ្រងការងាររបស់ក្រុមហ៊ុន លើកលែងតែមានសេចក្តីសម្រេចម្ចាស់ភាគហ៊ុនដែលអនុញ្ញាតឱ្យធ្វើសកម្មភាពណាមួយ និង/ឬដាក់កំហិតលើអំណាចរបស់អភិបាល ឬលើកលែងចំពោះសកម្មភាព ឬបញ្ហាដែលច្បាប់ ឬលក្ខន្តិកៈក្រុមហ៊ុននេះ តម្រូវឱ្យមានការសម្រេច ឬព្រមព្រៀងដោយម្ចាស់ភាគហ៊ុន។

(ខ) អភិបាលអាចផ្តល់អំណាច ឬលិខិតប្រគល់សិទ្ធិជូនកាន់បុគ្គលណាម្នាក់ ឱ្យចុះហត្ថលេខា ប្រគល់ជូន និង អនុវត្តទម្រង់បែបបទផ្លូវការទាំងឡាយណាដែលសំខាន់ បន្ទាប់បន្សំ ឬ ជាបែបបទរដ្ឋបាលសម្រាប់ការងារទាំងឡាយណា ដែលទទួលបានការយល់ស្របពីអភិបាល និង ពីម្ចាស់ភាគហ៊ុន ប្រសិនបើមានការតម្រូវណាមួយ។

(គ) អភិបាលត្រូវមានសិទ្ធិ និងអំណាចពេញលេញ ក្នុងការចុះហត្ថលេខាលើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់អភិបាល និងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ឬកំណត់ហេតុអង្គប្រជុំដែលអាចមានឯកសារមួយចំនួន (ឬឯកសារចម្លង) ក្នុងទម្រង់ដូចគ្នា ដែលឯកសារនីមួយៗត្រូវបានចុះហត្ថ-លេខាដោយអភិបាលមួយរូបឬច្រើនរូប។ បើក្រុមហ៊ុនមានអភិបាលតែមួយរូប អភិបាលនោះអាចចេញ

សេចក្តីសម្រេចដោយកត់កំណត់ហេតុ ហើយចុះហត្ថលេខាលើកំណត់ហេតុនោះ។ ហើយហត្ថ-លេខានោះ ត្រូវមានសុពលភាព និងអានុភាពដូចត្រូវបានសម្រេចនៅក្នុងអង្គប្រជុំផងដែរ។

(ឃ) អភិបាលក៏ត្រូវមានអំណាចដូចខាងក្រោមផងដែរៈ

(១) តែងតាំង និងដកហូតតំណែងរបស់បុគ្គលិកទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់បុគ្គលិកទាំងនោះ។

(២) កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់បុគ្គលិកទាំងនោះ។

(៣) កម្រិតប្រាក់បៀវត្ស ឬប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនទៅម្ចាស់ភាគហ៊ុនដើម្បីសុំសេចក្តីសម្រេច។

(៤) ចេញសញ្ញាប័ណ្ណ លិខិតស្នាមដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងនោះ។

(៥) ស្នើសុំការយល់ស្របពីម្ចាស់ភាគហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន។

(៦) ស្នើសុំការយល់ស្របពីម្ចាស់ភាគហ៊ុន លើកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និង បុគ្គលផ្សេងណាមួយ។

(៧) ស្នើសុំការយល់ស្របពីម្ចាស់ភាគហ៊ុន ដើម្បីលក់ទ្រព្យក្រុមហ៊ុនទាំងអស់ ឬមួយភាគ។

(៨) ស្នើសុំការយល់ស្របពីម្ចាស់ភាគហ៊ុនដើម្បីរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន។

(៩) ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌនៃទូទាត់របស់ភាគហ៊ុនប្រភេទនីមួយៗដែលមានសិទ្ធិទទួលភាគលាភ។

(១០) ខ្ចីប្រាក់ៗ

(១១) បោះចេញ បោះចេញសាជាថ្មី ឬ លក់មូលបត្ររបស់ក្រុមហ៊ុន។

(១២) ផ្តល់ការធានាក្នុងនាមក្រុមហ៊ុន។

(១៣) ចុះបញ្ជីហ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ ធានា ឬបើមិនដូច្នេះទេ បង្កើតសិទ្ធិប្រាតិភោគលើទ្រព្យទាំងអស់ ឬ ទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុន ដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន។

(១៤) រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗ និងដាក់លទ្ធផលប្រចាំឆ្នាំជូនម្ចាស់ភាគហ៊ុន។

(ង) មូលប្បទានប័ត្រ (cheques) ប័ណ្ណកំណត់សន្យា រូបិយាណត្តិ និងឧបករណ៍ដែលអាចជួញដូរបានដទៃទៀត និងវិក្កយបត្រទទួលប្រាក់ទាំងឡាយ ដែលបានទូទាត់មកក្រុមហ៊ុន ត្រូវតែមានចុះហត្ថ-លេខា ទទួល ចារ ដោយអភិបាលដែលពាក់ព័ន្ធ ឬ នៅតាមវិធីផ្សេងៗ ដែលអភិបាលកំណត់។

**៤.៣.២ ប្រធានក្រុមប្រឹក្សាភិបាល**

(ក) នៅក្នុងទំនាក់ទំនងជាមួយតតិយជន ប្រធានក្រុមប្រឹក្សាភិបាលត្រូវបានប្រគល់អំណាចជូនយ៉ាងទូលំទូលាយដើម្បីធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុននៅគ្រប់កាលៈទេសៈ។

(ខ) ប្រធានក្រុមប្រឹក្សាភិបាលមានអំណាច ជាតំណាងឱ្យក្រុមហ៊ុន និងចុះហត្ថលេខាលើរាល់ឯកសារ ដែលស្ថិតក្នុងវង្វង់ក្របខ័ណ្ឌនៃកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ហើយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះ តតិយជន។ ក្នុងការករណីដែលប្រើប្រាស់អំណាច នៅក្នុងប្រការណាមួយដែលផ្ទុយពីកិច្ចការដែលរៀបរាប់ខាងលើ ហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកជាមោឃៈ ហើយអ្នកប្រព្រឹត្តល្មើសនេះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបច្ច័យទាំងឡាយ ដែលមានកើតឡើងដោយសារឥរិយាបថទាំងនេះ ហើយអាចត្រូវបានដកហូតពីមុខតំណែងចេញពីប្រធានក្រុមប្រឹក្សាភិបាល។

(គ) ការចុះកិច្ចសន្យាដោយប្រធានក្រុមប្រឹក្សាភិបាលជាមួយតតិយជន លើកិច្ចការទាំងឡាយដែលស្ថិតនៅក្រៅកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ក៏បណ្តាលឱ្យក្រុមហ៊ុនជាប់កាតព្វកិច្ចចំពោះកិច្ចសន្យានោះដែរ។ ប៉ុន្តែក្នុងករណីនេះ ក្រុមហ៊ុនក៏អាចប្រកែកមិនទទួលខុសត្រូវបានដែរ ដោយកេភស្តុតាងបញ្ជាក់ថាតតិយជននោះ បានដឹងដោយច្បាស់ថា ប្រធានក្រុមប្រឹក្សាភិបាល បានចុះកិច្ចសន្យានោះហួសពីកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ជាក់ថា តតិយជននោះមិនអាចដោះសាថាខ្លួនមិនបានដឹងពីស្ថានភាពនេះ។ ដើម្បីរួចផុតពីការទទួលខុសត្រូវខាងលើ ក្រុមហ៊ុនមិនអាចយកការចុះផ្សាយសម្រង់លក្ខន្តិកៈក្រុមហ៊ុនក្នុងសារព័ត៌មាន មកធ្វើជាភស្តុតាងសម្រាប់ជាសម្អាងបានទេ។ ដូច្នេះនៅពេលកើតវិវាទបែប នេះត្រូវតែផ្តល់នូវឯកសារ សម្អាងនានាដូចជា លិខិតសម្អាងជាលាយលក្ខណ៍អក្សរ វត្ថុតាងផ្សេងៗ ។ល។

(ឃ) នៅក្នុងទំនាក់ទំនងជាមួយម្ចាស់ភាគហ៊ុន ប្រធានក្រុមប្រឹក្សាភិបាលអាចធ្វើរាល់កិច្ចការ សម្រាប់ជាផលប្រយោជន៍របស់ក្រុមហ៊ុន។ ក៏ប៉ុន្តែ កិច្ចការខ្លះដូចមានបញ្ជាក់ខាងក្រោមនេះ ត្រូវតែមានការអនុញ្ញាតដោយសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន រួមមានការទិញ ការលក់ ការដោះដូរអចលនទ្រព្យ ឬមូលនិធិពាណិជ្ជកម្មរបស់ក្រុមហ៊ុន ការចុះកិច្ចសន្យាខ្ចីបុលក្នុងនាមក្រុមហ៊ុន ការខ្ចីឥណទានពីធនាគារ ឬតតិយជន ការធ្វើហ៊ីប៉ូតែកលើសង្ហារឹមភ័ណ្ឌរបស់ក្រុមហ៊ុន ឬការបញ្ចាំមូលនិធិពាណិជ្ជកម្ម ឬការចូលរួមសហការក្នុងការបង្កើតក្រុមហ៊ុននានា ការកែប្រែលក្ខន្តិកៈ។

(ង) តាមរយៈលិខិតសម្អាងជាលាយលក្ខណ៍អក្សរ ក្រុមប្រឹក្សាភិបាលអាចតែងតាំង គណៈកម្មាធិការណាមួយឱ្យទទួលចាត់ចែងនូវការងារណាមួយ ឬភារកិច្ចមួយចំនួន ជំនួសខ្លួន និងក្រោមការត្រួតពិនិត្យរបស់ខ្លួនផ្ទាល់។

## ៩.៤ សន្និបាតក្រុមប្រឹក្សាភិបាល

(ក) សន្និបាតក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងយ៉ាងតិច រាល់៣(បី)ខែ ម្តង។

(ខ) ប្រធានក្រុមប្រឹក្សាភិបាល ឬក្នុងករណីបន្ទាន់ ១/៣ (មួយភាគបី) នៃអភិបាល អាចកោះប្រជុំសន្និបាតក្រុមប្រឹក្សាភិបាល បានដោយ ផ្ញើលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរទៅកាន់អភិបាលទាំងអស់ យ៉ាងហោចណាស់ ១៤ (ដប់បួន) ថ្ងៃមុនថ្ងៃប្រជុំ។

(គ) លិខិតអញ្ជើញសម្រាប់អភិបាលដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែផ្ញើតាមប្រៃសណីយ៍ ឬអ្នកនាំសារផ្ទាល់របស់ក្រុមហ៊ុន ឬទូរសារ ឬតាមរយៈមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចនានា។

(ឃ) លិខិតអញ្ជើញសម្រាប់អភិបាលដែលរស់នៅបរទេសត្រូវផ្ញើ តាមការដឹកជញ្ជូនហ័សតាមយន្តហោះ ឬតាមរយៈមធ្យោបាយទំនាក់ទំនងដោយទូរសារ។ លិខិតអញ្ជើញទាំងនោះត្រូវកំណត់យ៉ាងច្បាស់ពីទីតាំង កាលបរិច្ឆេទ និងពេលវេលានៃសន្និបាត និងចែងអំពីរបៀបវារៈសម្រាប់ការពិភាក្សា និងសម្រេចផងដែរ។

(ង) អភិបាលទាំងអស់ត្រូវរក្សាអាសយដ្ឋានជាក់លាក់បច្ចុប្បន្ននិងពេញលេញរបស់ខ្លួន និងព័ត៌មានទាក់ទងលំអិតនៅទីស្នាក់ការរបស់ក្រុមហ៊ុន។ ពុំដូច្នេះទេ អភិបាលនោះ មិនអាចប្តឹងតវ៉ាបានឡើយ ប្រសិនបើ ខ្លួនមិនបានទទួលសេចក្តីជូនដំណឹងពីកិច្ចប្រជុំសន្និបាតណាមួយ។

## ៤.៥ កូរ៉ុមសម្រាប់សន្និបាតក្រុមប្រឹក្សាភិបាល

(ក) កូរ៉ុមរបស់សន្និបាតក្រុមប្រឹក្សាភិបាលគឺត្រូវតែជាចំនួនភាគច្រើននៃចំនួនអភិបាលសរុប។

(ខ) អភិបាលម្នាក់អាចប្រគល់សិទ្ធិជូនអភិបាលម្នាក់ទៀតធ្វើជាតំណាងរបស់ខ្លួនក្នុងការចូលរួម និងបោះឆ្នោតនៅក្នុងសន្និបាត ដោយមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ដែរបានចុះហត្ថលេខាដោយអភិបាលដែរខ្លួនបានធ្វើតំណាងអោយ។

## ៤.៦ ទម្រង់នៃសន្និបាត

សន្និបាតក្រុមប្រឹក្សាភិបាល ដែលធ្វើឡើងតាមរយៈទូរស័ព្ទ ឬមធ្យោបាយអេឡិចត្រូនិចផ្សេងៗ រួមទាំងការទាក់ទងតាមសម្លេង ឬសម្លេងនិងរូបភាព ទោះបីជាអភិបាលមិនមានវត្តមាននៅកន្លែងតែមួយ នាពេលប្រជុំក៏ដោយ ក៏ត្រូវចាត់ទុកជាមានសុពលភាព និងមានអានុភាពដូចក្នុងករណីដែលសេចក្តីសម្រេចបានសម្រេចនៅក្នុងមហាសន្និបាតក្រុមប្រឹក្សាភិបាលដែលមានកោះប្រជុំត្រឹមត្រូវដែរ។

## ៤.៧ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

(ក) ដោយស្របតាមលក្ខន្តិកៈក្រុមហ៊ុននេះ ឬការតម្រូវការតាមច្បាប់ សេចក្តីសម្រេចដែលសម្រេចនៅសន្និបាតណាមួយនៃក្រុមប្រឹក្សាភិបាល ត្រូវតែធ្វើឡើងតាមសម្លេងភាគច្រើននៃអភិបាលដែលមានវត្តមាននៅក្នុងសន្និបាតនោះៗ សេចក្តីសម្រេចដោយសម្លេងភាគច្រើននៃអភិបាល គឺត្រូវបានចាត់ទុកថាជាសេចក្តីសម្រេចរបស់អភិបាល។

(ខ) អភិបាលមិនត្រូវបោះឆ្នោតចំពោះប្រតិបត្តិការណាមួយ ឬការស្នើប្រតិបត្តិការណាមួយ ដែលអភិបាលនោះទទួលបានផលប្រយោជន៍ ឬទាក់ទងទៅនឹងបញ្ហាណាមួយដែលកើតឡើងពីប្រតិបត្តិការនោះ ឬការស្នើប្រតិបត្តិការនោះឡើយ។ ប្រសិនបើអភិបាលនោះបានបោះឆ្នោតទៅលើប្រតិបត្តិការណាមួយ ឬការស្នើប្រតិបត្តិការណាមួយ ដូចដែលបានបញ្ជាក់ខាងលើ សម្លេងបោះឆ្នោតរបស់អភិបាលនោះមិនត្រូវបានរាប់នោះទេ។

## ៤.៨ សេចក្តីសម្រេចរបស់អភិបាលជាលាយលក្ខណ៍អក្សរ

(ក) សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលត្រូវបានចុះហត្ថលេខាដោយអភិបាលទាំងអស់ ដែលមានសិទ្ធិ ទទួលបានសេចក្តីជូនដំណឹងអំពីសន្និបាតក្រុមប្រឹក្សាភិបាល គឺមានសុពលភាព និង អានុភាពដូចដែលសេចក្តីសម្រេចដែលបានសម្រេចនៅក្នុងសន្និបាតក្រុមប្រឹក្សាភិបាល ដែលបានកោះហៅនិងបើកការប្រជុំយ៉ាងត្រឹមត្រូវផងដែរ។

(ខ) សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរណាមួយ ស្របតាមកថាខណ្ឌ (ក) ខាងលើ អាចធ្វើឡើងជាឯកសារច្រើនក្នុងទម្រង់ដូចគ្នា ដែលឯកសារនីមួយៗត្រូវបានចុះហត្ថលេខាដោយអភិបាលមួយរូបឬច្រើនរូប។

(គ) បើក្រុមហ៊ុនមានអភិបាលតែមួយរូប អភិបាលនោះអាចចេញសេចក្តីសម្រេចដោយកត់កំណត់ហេតុ ហើយចុះហត្ថលេខាលើកំណត់ហេតុនោះ។

### ៤.៩ កំណត់ហេតុ

អភិបាលត្រូវចាត់ចែងរៀបចំ និងចុះបញ្ជី សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សាភិបាល និងម្ចាស់ហ៊ុន កំណត់ហេតុនៃសន្និបាត ដំណើរការនៃមហាសន្និបាតម្ចាស់ហ៊ុន និង សន្និបាតក្រុមប្រឹក្សាភិបាល ទៅក្នុងកំណត់ហេតុក្រុមហ៊ុន ដោយមានបញ្ជាក់នូវ ទីកន្លែង កាលបរិច្ឆេទ និង ពេលវេលានៃសន្និបាត វត្តមានរបស់អភិបាល និង ម្ចាស់ហ៊ុន។

## ប្រការ ៥

## សេចក្តីសម្រេចរបស់សមាជិក

លើកលែងតែរាល់បញ្ហាដែលត្រូវបានអនុញ្ញាតឱ្យ សម្រេចដោយក្រុមប្រឹក្សាភិបាល សេចក្តីសម្រេចទាំងអស់ ជាអំណាចរបស់ម្ចាស់ភាគហ៊ុន ដែលត្រូវទទួលខុសត្រូវផ្ទាល់ ចំពោះតតិយជន។

## ប្រការ ៦

## សវនករ

**៦.១** ម្ចាស់ភាគហ៊ុនមានសិទ្ធិតែងតាំងឬដកចេញ សវនករម្នាក់ ឬច្រើននាក់ សម្រាប់ក្រុមហ៊ុន ស្របតាមច្បាប់ដែលមានជាធរមាន។

**៦.២** សវនករត្រូវទទួលបានប្រាក់តម្រៃស្របតាមច្បាប់ដែលមានជាធរមាន។ សវនករ ត្រូវមានសិទ្ធិ និងកាតព្វកិច្ចរបស់ដូចដែលបានកំណត់ដោយច្បាប់ជាធរមាន។

## ប្រការ ៧

## គណនីចរន្តរបស់ក្រុមហ៊ុន

បើសិនជាមានការចាំបាច់ ម្ចាស់ភាគហ៊ុន អាចទុកប្រាក់នៅក្នុងគណនីចរន្តរបស់ក្រុមហ៊ុន ដែលការប្រាក់ត្រូវស្របតាមអាត្រាការប្រាក់ដែលកំណត់ដោយច្បាប់។ ម្ចាស់ភាគហ៊ុនមិនត្រូវបានអនុញ្ញាតឱ្យខ្ចីប្រាក់ពីក្រុមហ៊ុនឡើយ។

## ប្រការ ៨

## ឆ្នាំសារពើពន្ធនៃក្រុមហ៊ុន និងការប្រកាសលទ្ធផលនៃអាជីវកម្ម ការផ្លាស់ប្តូរទ្រទ្រង់ទ្រាយ

### ៨.១ សារពើពន្ធនៃក្រុមហ៊ុន

ឆ្នាំសារពើពន្ធចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ដោយលើកលែងឆ្នាំសារពើពន្ធដំបូងដែលត្រូវចាប់ផ្តើមនាកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន និងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំបង្កើតក្រុមហ៊ុន។

## ៨.២ ការប្រកាសលទ្ធផលនៃអាជីវកម្ម

(ក) រៀងរាល់ចុងឆ្នាំនៃប្រតិទិននីមួយៗ ក្រុមហ៊ុនត្រូវចាត់ចែងរៀបចំបញ្ជីសារពើភ័ណ្ឌពេញលេញមួយ ធ្វើតារាងតុល្យការ និងរបាយការណ៍ប្រាក់ចំណូល។ របាយការណ៍ប្រាក់ចំណូលត្រូវរាប់បញ្ចូលទាំងចំណូល និងចំណាយ ហើយបង្ហាញពីប្រាក់ចំណេញ ឬ ខាតរបស់ក្រុមហ៊ុន។

(ខ) យ៉ាងតិច ៥% (ប្រាំភាគរយ) នៃប្រាក់ចំណេញរបស់ក្រុមហ៊ុនត្រូវមានការដកហូតទុកពីប្រាក់ចំណេញ ដើម្បីបង្កើតជាមូលនិធិបម្រុង។ ការដកហូតយកភាគនៃប្រាក់ចំណេញនេះត្រូវបញ្ចប់ កាលបើមូលនិធិបម្រុងនេះមានគ្រប់ចំនួន ១០% (ដប់ភាគរយ) នៃដើមទុនចុះបញ្ជីដំបូងរបស់ក្រុមហ៊ុន។

# ប្រការ ៩

# ការខាតបង់ ការរំលាយក្រុមហ៊ុន ការផ្លាស់ប្តូរទ្រង់ទ្រាយ វិវាទ សោហ៊ុយចំណាយ

## ៩.១ ការខាតបង់

(ក) ប្រសិនបើរបាយការណ៍គណនេយ្យ បង្ហាញឱ្យឃើញថាក្រុមហ៊ុន ទទួលរងការខាតបង់ក្នុងចំនួនទឹកប្រាក់លើសពីពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូង ម្ចាស់ភាគហ៊ុនត្រូវសម្រេចរំលាយក្រុមហ៊ុន។

(ខ) ការរំលាយនេះត្រូវធ្វើឡើង ប្រសិនបើស្ថានការណ៍មិនអាចធ្វើឱ្យមានប្រក្រតីភាពឡើងវិញ បានទេក្នុងរយៈពេល ១ (មួយ) ឆ្នាំបន្ទាប់ពីបានពិនិត្យឃើញនូវការខាតបង់នេះ។

(គ) ក្រុមហ៊ុនក៏អាចត្រូវរំលាយបានដែរតាមផ្លូវតុលាការ ដោយមូលហេតុត្រឹមត្រូវ។

## ៩.២ ការរំលាយ និងជម្រះបញ្ជីសហគ្រាស

ក្នុងករណីរំលាយក្រុមហ៊ុនដែលបណ្តាលមកពីមរណភាព ឬការរំលាយ ឬការបាត់បង់សមត្ថភាពរបស់ម្ចាស់ភាគហ៊ុន ឬការសម្រេចរបស់តុលាការលើមោឃកម្មម្ចាស់ភាគហ៊ុន ឬការខាតបង់លើសចំនួនពាក់កណ្តាលនៃដើមទុនចុះបញ្ជី ក្រុមហ៊ុនត្រូវធ្វើការជម្រះបញ្ជី។ ការរំលាយនេះនឹងមានឥទ្ធិពលលើតតិយជនលុះត្រាតែមានការចុះផ្សាយក្នុងបញ្ជីពាណិជ្ជកម្ម។

## ៩.៣ មរណភាព - ការហាមឃាត់ - ធនក្ស័យនៃម្ចាស់ភាគហ៊ុនម្នាក់

មរណភាព អសមត្ថភាព ការហាមឃាត់ ធនក្ស័យរបស់ម្ចាស់ភាគហ៊ុនណាម្នាក់ដែលជារូបវន្តបុគ្គល ព្រមទាំងការកែទម្រង់ឡើងវិញ ឬការជម្រះបញ្ជីតាមផ្លូវតុលាការរបស់ម្ចាស់ភាគហ៊ុនមួយដែលជានីតិបុគ្គល មិនបណ្តាលឱ្យក្រុមហ៊ុនរំលាយឡើយ។ ក៏ប៉ុន្តែ បើព្រឹត្តការណ៍ណាមួយខាងលើ បានកើតមានឡើងចំពោះអភិបាល អភិបាលនេះត្រូវបានបញ្ឈប់ពីតំណែងជាអភិបាលភ្លាម។

## ៩.៤ ការផ្លាស់ប្តូរទ្រង់ទ្រាយ

(ក) ទ្រង់ទ្រាយរបស់ក្រុមហ៊ុន អាចត្រូវបានផ្លាស់ប្តូរពីសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបាន កាលបើមានរូបវន្តបុគ្គល ឬ នីតិបុគ្គលមួយ ឬ ច្រើនទទួលបានការយល់ព្រមពីម្ចាស់ភាគហ៊ុនឱ្យចូលជាសមាជិក។

(ខ) រាល់សេចក្តីសម្រេចផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន ត្រូវតែមានធ្វើជាមុននូវរបាយការណ៍លើស្ថានភាពរបស់ក្រុមហ៊ុន ទោះបីជាក្រុមហ៊ុនមិនទាន់មានសវនករនៅឡើយក៏ដោយ។

## ៩.៥ វិវាទ

រាល់បណ្ដឹងជំនួសមុខ ឬវិវាទ ដែលអាចកើតឡើងរវាងម្ចាស់ហ៊ុន និងអភិបាល និងជាមួយ បុគ្គលិកក្រុមហ៊ុន នៅក្នុងចិរវេលាក្រុមហ៊ុន ឬនៅក្នុងរយៈពេលជម្រះបញ្ជី ត្រូវធ្វើការដោះស្រាយដោយការសម្រុះសម្រួលគ្នាក្នុងក្រុមហ៊ុន។ ក្នុងករណីមិនអាចសម្រុះសម្រួលគ្នាបានទេ ភាគីវិវាទអាចដាក់ពាក្យមកការិយាល័យទទួលពាក្យបណ្ដឹងនៃក្រសួងពាណិជ្ជកម្ម ឬទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងទៅតុលាការដែលមានសមត្ថកិច្ច។

## ៩.៦ សោហ៊ុយចំណាយ

ចំណាយក្នុងការបង្កើតក្រុមហ៊ុននេះ ត្រូវបញ្ចូលក្នុងបញ្ជីចំណាយរបស់ក្រុមហ៊ុន។

ចំឡងត្រឹមត្រូវ៖ ផ្តល់ដោយក្រសួងពាណិជ្ជកម្ម

# ឧបសម្ព័ន្ធទី១

## ព័ត៌មានសហគ្រាស

- នាមករណ៍សហគ្រាស (ជាភាសាខ្មែរ) ៖
- នាមករណ៍សហគ្រាស (ជាភាសាអង់គ្លេស)៖
- ទ្រង់ទ្រាយ ៖
- កម្មវត្ថុអាជីវកម្ម (លេខសម្គាល់ និងការពណ៌នារបស់កម្មវត្ថុអាជីវកម្ម)៖
- អាសយដ្ឋានចុះបញ្ជី ៖
- ដើមទុនចុះបញ្ជី និងតម្លៃចារឹកលើបណ្ណ ៖
- ព័ត៌មានម្ចាស់ហ៊ុន៖

| ឈ្មោះ | អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន | ចំនួនហ៊ុន និង ភាគរយនៃភាគហ៊ុន | ហត្ថលេខា (បានអាន និងយល់ព្រម) |
|---|---|---|---|
| | | | |

- ព័ត៌មានអភិបាល៖

| ឈ្មោះ | អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន | តួនាទី | ហត្ថលេខា (បានអាន និងយល់ព្រម) |
|---|---|---|---|
| 1. | | | |
| 2. | | | |
| 3. | | | |

- តារាងឈ្មោះម្ចាស់ភាគហ៊ុន ឬអភិបាល មានសិទ្ធិតែងតាំង នាយកប្រតិបត្តិ ឬប្រធានសាខា ឬបើក និងប្រើប្រាស់គណនីធនាគារសហគ្រាស៖

| ឈ្មោះ | អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន | តួនាទី | ហត្ថលេខា (បានអាន និងយល់ព្រម) |
|---|---|---|---|
| ១. | | | |
| ២. | | | |
| ៣. | | | |

# លក្ខន្តិកៈក្រុមហ៊ុន

# MEMORANDUM AND ARTICLES OF ASSOCIATION

គំរូលក្ខន្តិកៈដែលតម្រូវឱ្យមានសញ្ជាតិខ្មែរលើស៥១% នៃម្ចាស់ភាគហ៊ុន

## [ឈ្មោះ ក្រុមហ៊ុន]

## [COMPANY NAME]

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

Private Limited Company

# លក្ខន្តិកៈក្រុមហ៊ុន

## ប្រការ ១

## ព័ត៌មានក្រុមហ៊ុន

ចាប់ពីថ្ងៃបានចុះបញ្ជីពាណិជ្ជកម្មតាមបញ្ញត្តិច្បាប់ ក្រុមហ៊ុននេះមាននីតិបុគ្គល ហើយស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងក្រោមការកំណត់នៃប្រការទាំងឡាយ ដែលមានចែងក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនត្រូវបន្តមាន រហូតដល់ការរំលាយក្រុមហ៊ុនត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ ការរំលាយក្រុមហ៊ុននេះ ត្រូវធ្វើឡើងតាមសេចក្តីសម្រេចពិសេសរបស់ម្ចាស់ភាគហ៊ុន តំណាងដោយសម្លេងឆ្នោត ២/៣ (ពីរភាគបី) នៃសម្លេងឆ្នោតរបស់ម្ចាស់ភាគហ៊ុនដែលបានសម្រេចអំពីបញ្ហានោះ ឬបញ្ជូសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់។

ព័ត៌មានក្រុមហ៊ុនរួមមាន នាមករណ៍ ទ្រង់ទ្រាយ កម្មវត្ថុអាជីវកម្ម អាសយដ្ឋាន ដើមទុនចុះបញ្ជី តម្លៃចារឹកលើបណ្ណភាគហ៊ុន ព័ត៌មានម្ចាស់ហ៊ុន និងព័ត៌មានអភិបាល ត្រូវបានជូនភ្ជាប់ដូចក្នុងឧបសម្ព័ន្ធទី១ នៃលក្ខន្តិកៈក្រុមហ៊ុននេះ។ រាល់ការកែប្រែព័ត៌មានក្រុមហ៊ុនដូចជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ត្រូវធ្វើឡើងតាមសេចក្តីសម្រេច ដូចមានចែងក្នុងលក្ខន្តិកៈនេះ ឬបទប្បញ្ញត្តិជាធរមាន។

## ប្រការ ២

## ដើមទុន – ភាគហ៊ុន – ម្ចាស់ភាគហ៊ុន

### ២.១ ដើមទុន ភាគហ៊ុន

(ក) ចំនួនដើមទុនសរុបទាំងអស់នេះ ត្រូវបង់ចូលមកក្នុងគណនីរបស់ក្រុមហ៊ុន ជាសាច់ប្រាក់ទាំងស្រុង និងគ្រប់ចំនួនដោយម្ចាស់ភាគហ៊ុនទៅតាមសមមាត្រភាគហ៊ុនផ្ទាល់របស់ខ្លួនម្នាក់ៗ ហើយការបង់បញ្ចូលនេះត្រូវបានម្ចាស់ភាគហ៊ុនទាំងអស់គ្នាទទួលស្គាល់ថា ពិតជាបានបង់គ្រប់ចំនួនមែន។

(ខ) ភាគហ៊ុន ត្រូវបានបែងចែក និងចុះលេខជូនម្ចាស់ភាគហ៊ុនម្នាក់ៗ ទៅតាមសមាមាត្រនៃដើមទុនរៀងៗខ្លួន។

(គ) ម្ចាស់ភាគហ៊ុនទាំងអស់ប្រកាសថាខ្លួនបានយល់ព្រមលើភាគហ៊ុន ដែលបានបង្កើតឡើង និងបានបែងចែកតាមសមាមាត្រដូចជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ព្រមទាំងប្រកាសថាបានបង់បញ្ចូលគ្រប់ចំនួនមកក្នុងក្រុមហ៊ុន។ គ្រប់ភាគហ៊ុនទាំងអស់ ត្រូវបានចុះបញ្ជីទៅតាមចំណែកនៃម្ចាស់ភាគហ៊ុន។

(ឃ) ដើម្បីអាចទទួលសិទ្ធិជាម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុន ដរាបណាបុគ្គលនោះមានកម្មសិទ្ធិលើភាគហ៊ុនដែលបានបែងចែកជូនទៅខ្លួន។ ក្នុងករណីចង់ធ្វើអនុប្បទានភាគហ៊ុន ត្រូវតែមានការព្រមព្រៀងរវាងម្ចាស់ភាគហ៊ុនទៅតាមលក្ខខណ្ឌ ដែលមានចែងក្នុងប្រការ៣.២ នៃលក្ខន្តិកៈនេះ។

### ២.២ ការបង្កើនដើមទុន ការបន្ថយដើមទុន

**២.២.១ ការបង្កើនដើមទុន**

(ក) ដើមទុនចុះបញ្ជី អាចត្រូវបានបង្កើនតាមគ្រប់វិធីដែលច្បាប់អនុញ្ញាត ព្រមទាំងឱ្យស្របទៅតាមសេចក្តីសម្រេចពិសេសរបស់ម្ចាស់ភាគហ៊ុន ដូចខាងក្រោមៈ

(១) បោះភាគហ៊ុនថ្មីៗបន្ថែម ដែលត្រូវបង់ជាសាច់ប្រាក់ ឬ ជាវត្ថុ។

(២) បង្វិលបញ្ចូលមួយភាគ ឬ ទាំងស្រុងនៃមូលនិធិបម្រុងមកក្នុងដើមទុន។ឬ

(៣) តាមគ្រប់វិធីដទៃទៀតដែលច្បាប់អនុញ្ញាត។

(ខ) ក្នុងករណីតម្លើងដើមទុន តាមវិធីបោះភាគហ៊ុនបន្ថែមក្នុងក្រុមហ៊ុន ការទិញភាគហ៊ុនបន្ថែមនេះ ត្រូវធ្វើឡើងដោយស្របទៅតាមមាត្រា ៣ និងលក្ខខណ្ឌផ្សេងទៀតដែលបានចែងក្នុងលក្ខន្តិកៈនេះ។

(គ) ក្នុងករណីបង្កើនដើមទុនដោយការបង់ភាគហ៊ុនជាសាច់ប្រាក់ លើកលែងតែសេចក្តីសម្រេចពិសេសបានចែងលក្ខខណ្ឌផ្ទុយពីនេះ ទាក់ទងនឹងការតម្លើងដើមទុន រាល់ម្ចាស់ភាគហ៊ុនទាំងអស់មានសិទ្ធិជ្រើសរើសយកចំនួនភាគហ៊ុនថ្មីទៅតាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនមាន ទៅតាមនីតិវិធីមួយដែលបានកំណត់ដោយសេចក្តីសម្រេចនៃមហាសន្និបាតម្ចាស់ភាគហ៊ុន។

(ឃ) ក្នុងករណីបង្កើនដើមទុនដោយការបង់ភាគហ៊ុនជាវត្ថុ ដើមទុនជាវត្ថុនេះត្រូវវាយតម្លៃដោយសវនករ កាលណាតម្លៃភាគហ៊ុននេះលើសពី៤០% (សែសិបភាគរយ) នៃដើមទុនចុះបញ្ជី។ ប្រសិនបើតម្លៃភាគហ៊ុនជាវត្ថុ នេះមានតម្លៃតិចជាង៤០% (សែសិបភាគរយ) នៃដើមទុនចុះបញ្ជី ការវាយតម្លៃភាគហ៊ុននេះអាចធ្វើឡើងដោយម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនទាំងអស់។

**២.២.២ ការបន្ថយដើមទុន**

ដើមទុនអាចត្រូវបានបន្ថយ អាស្រ័យដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ភាគហ៊ុន ដែលសម្រេចទៅតាមលក្ខខណ្ឌបញ្ញត្តិនៃច្បាប់។ ក៏ប៉ុន្តែ ការបន្ថយដើមទុនមិនត្រូវឱ្យប៉ះពាល់ដល់សមភាព នៃម្ចាស់ហ៊ុន ឬក៏មិនត្រូវឱ្យដើមទុននៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូង និងទាបជាងដើមទុនកំណត់ដោយច្បាប់ឡើយ។ ការបន្ថយដើមទុន ត្រូវតែអនុញ្ញាតដោយមហាសន្និបាតម្ចាស់ភាគហ៊ុន។

**២.៣ មហាសន្និបាតម្ចាស់ភាគហ៊ុន**

**២.៣.១ ការប្រព្រឹត្តឡើងនៃមហាសន្និបាតម្ចាស់ភាគហ៊ុន**

មហាសន្និបាតម្ចាស់ភាគហ៊ុនត្រូវប្រារព្ធឡើង យ៉ាងហោចណាស់ ១ (មួយ) ឆ្នាំម្តង ក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាភិបាល។

**២.៣.២ ការកោះមហាសន្និបាតម្ចាស់ភាគហ៊ុន**

មហាសន្និបាតម្ចាស់ភាគហ៊ុនអាចកោះប្រជុំនៅពេលណាក៏បាន ដោយសម្លេងភាគច្រើនរបស់ក្រុមប្រឹក្សាភិបាល ឬដោយប្រធានក្រុមប្រឹក្សាភិបាល ឬដោយសម្លេងភាគច្រើននៃអំណាចបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុន ឬ ដោយសវនករ។

**២.៣.៣ ទម្រង់ និងទីកន្លែងនៃមហាសន្និបាតម្ចាស់ភាគហ៊ុន**

(ក) សម័យប្រជុំនៃមហាសន្និបាតត្រូវធ្វើឡើងនៅទីស្នាក់ការក្រុមហ៊ុន ឬនៅកន្លែងដទៃទៀតនៅក្នុងប្រទេសកម្ពុជាដូចមានបញ្ជាក់ក្នុងលិខិតអញ្ជើញ ឬនៅទីកន្លែងណាមួយផ្សេងទៀតនៅក្រៅប្រទេសកម្ពុជាដែលព្រមព្រៀងដោយម្ចាស់ភាគហ៊ុនទាំងអស់។ លិខិតអញ្ជើញត្រូវមានចែងពីកាលបរិច្ឆេទ របៀបវារៈ និងទីកន្លែងនៃមហាសន្និបាត និងផ្ញើជូនម្ចាស់ហ៊ុន ទាំងអស់រយៈពេល ២០ (ម្ភៃ) ថ្ងៃ ទៅ ៥០ (ហាសិប) ថ្ងៃមុនថ្ងៃប្រជុំ។

(ខ) រាល់ម្ចាស់ភាគហ៊ុន ត្រូវតម្កល់ទុកនៅក្នុងទីស្នាក់ការក្រុមហ៊ុន នូវអាសយដ្ឋានជាក់លាក់បច្ចុប្បន្នរបស់ខ្លួន។ បើពុំដូច្នេះទេ ម្ចាស់ហ៊ុននោះមិនអាចប្ដឹងតវ៉ាបានឡើយ ប្រសិនបើខ្លួនមិនបានទទួលសេចក្ដីជូនដំណឹងពីកិច្ចប្រជុំណាមួយ។

(គ) ម្ចាស់ភាគហ៊ុនអាចចូលរួមនៅក្នុងមហាសន្និបាតនៃម្ចាស់ភាគហ៊ុនបានតាមរយៈការប្រជុំតាមវីដេអូ ឬការប្រជុំតាមទូរស័ព្ទដៃ ឬតាមរយៈឧបករណ៍ទំនាក់ទំនងស្រដៀងគ្នានេះ ដែលអាចធ្វើឱ្យម្ចាស់ភាគហ៊ុនដែលចូលរួមក្នុងមហាសន្និបាត អាចស្ដាប់លឺ និងត្រូវបានស្ដាប់លឺដោយម្ចាស់ភាគហ៊ុនទាំងអស់នោះ ដោយ មិនចាំបាច់មានវត្តមានម្ចាស់ភាគហ៊ុនផ្ទាល់ឡើយ។ ការចូលរួមមហាសន្និបាតតាមរបៀបបែបនេះ ត្រូវបានចាត់ទុកថាជាការមានវត្តមានដោយផ្ទាល់ក្នុងមហាសន្និបាតដែរ។ ម្ចាស់ភាគហ៊ុនដែលបានចូលរួមនៅក្នុងមហាសន្និបាតបែបនេះ ត្រូវបានរាប់បញ្ចូលក្នុងកូរ៉ុមសម្រាប់មហាសន្និបាតនេះ ហើយដោយគ្រប់តាមចំនួនកូរ៉ុមដែលមានកំណត់ក្រោមលក្ខន្តិកៈនេះ រាល់សេចក្ដីសម្រេច ដែលបានព្រមព្រៀងដោយម្ចាស់ភាគហ៊ុននៅក្នុងមហាសន្និបាតបែបនេះ ត្រូវចាត់ទុកថាមានអានុភាពដូចសេចក្ដីសម្រេចដែលបានសម្រេចនៅក្នុងមហាសន្និបាតដែលបានកោះហៅ និង មានវត្តមានផ្ទាល់របស់ម្ចាស់ភាគហ៊ុនផងដែរ។ មហាសន្និបាតនៃម្ចាស់ភាគហ៊ុនដែលបានធ្វើឡើងតាមរយៈទូរស័ព្ទដៃ ឬការប្រជុំតាមវីដេអូ ឬតាមរយៈឧបករណ៍ទំនាក់ទំនងស្រដៀងនេះដូចដែលបានរៀបរាប់ខាងលើ ត្រូវបានចាត់ទុកថា បានធ្វើឡើងនៅទីកន្លែងដែលបានព្រមព្រៀងដោយម្ចាស់ភាគហ៊ុនដែលចូលរួមក្នុងមហាសន្និបាតនោះ ប៉ុន្តែយ៉ាងហោចណាស់ម្ចាស់ភាគហ៊ុនមួយរូបដែលមានវត្តមាននៅក្នុងមហាសន្និបាតនោះ ត្រូវមានវត្តមាននៅទីកន្លែងដែលបានកំណត់សម្រាប់មហាសន្និបាតក្នុងអំឡុងពេលនៃមហាសន្និបាតនោះ។

## ២.៣.៤ កូរ៉ុមសម្រាប់មហាសន្និបាតម្ចាស់ភាគហ៊ុន

(ក) កូរ៉ុមនៃមហាសន្និបាតម្ចាស់ភាគហ៊ុន គឺវត្តមាននៃម្ចាស់ភាគហ៊ុនកាន់កាប់ភាគហ៊ុនភាគច្រើនដែលតំណាងឱ្យ៧៥%(ចិតសិបប្រាំភាគរយ) នៃភាគហ៊ុនដែលមានសម្លេងបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុនក្នុងមហាសន្និបាត ដោយមានវត្តមានដោយផ្ទាល់ ឬដោយតំណាងជាអាណត្តិគាហកៈ។

(ខ) ក្នុងករណីដែលមហាសន្និបាតលើកទីមួយ មិនបានទទួលបានកូរ៉ុមគ្រប់គ្រាន់តាមចំនួនកំណត់ខាងលើនេះទេ ត្រូវកោះប្រជុំមហាសន្និបាតលើកទីពីរក្នុងអំឡុងពេលយ៉ាងហោចណាស់ ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃមហាសន្និបាតដំបូង ដោយគោរពតាមរបៀបវារៈនៃមហាសន្និបាតដំបូង។

(គ) កូរ៉ុមនៃមហាសន្និបាតលើកទីពីរ ត្រូវបានកំណត់ត្រឹមវត្តមានម្ចាស់ភាគហ៊ុនកាន់កាប់ភាគហ៊ុន ដែលតំណាងឱ្យសម្លេងយ៉ាងតិច ៥១% (ហាសិបមួយ ភាគរយ) នៃភាគហ៊ុនដែលមានសម្លេងបោះឆ្នោត។

## ២.៣.៥ សេចក្ដីសម្រេចរបស់ម្ចាស់ភាគហ៊ុន

ដោយស្របតាមតម្រូវការបន្ថែមដែលកំណត់ដោយច្បាប់ ឬដោយបានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន សេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ភាគហ៊ុន អាចយកជាការបាន លុះត្រាតែមានការយល់ព្រមពីសម្លេងភាគច្រើនធម្មតានៃសម្លេងឆ្នោតសរុបពីម្ចាស់ហ៊ុនដែលមានវត្តមានក្នុងអង្គប្រជុំ។

### ២.៣.៦ អ្នកតំណាង

ម្ចាស់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតតាមរយៈអ្នកតំណាងនៅក្នុងមហាសន្និបាតម្ចាស់ភាគហ៊ុន។

### ២.៣.៧ សិទ្ធិបោះឆ្នោត

(ក) ម្ចាស់ភាគហ៊ុនទាំងអស់មានសិទ្ធិពេញលេញនៅក្នុងការបោះឆ្នោត ដោយមិនគិតពីឋានៈណា ឬចំនួនភាគហ៊ុនដែលខ្លួនកាន់កាប់។ ម្ចាស់ភាគហ៊ុនមានសិទ្ធិផ្តល់សម្លេងឆ្នោតស្មើនឹងចំនួនភាគហ៊ុនដែលខ្លួនកាន់កាប់ ដោយគ្មានការកម្រិតអ្វីឡើយ។ ម្ចាស់ភាគហ៊ុនម្នាក់អាចចាត់តាំងឱ្យសហព័ទ្ធខ្លួនចូលរួមជាតំណាងនៅក្នុងការបោះឆ្នោតបាន។ ម្ចាស់ហ៊ុនម្នាក់អាចប្រគល់សិទ្ធិជូនម្ចាស់ហ៊ុនម្នាក់ទៀតធ្វើជាតំណាងរបស់ខ្លួនបានដែរ។

(ខ) ទោះបីក្នុងករណីណាក៏ដោយ ម្ចាស់ភាគហ៊ុនម្នាក់អាចប្រគល់សិទ្ធិជូនតតិយជនណាម្នាក់ (រួមបញ្ចូលទាំងសហព័ទ្ធរបស់ខ្លួន) ធ្វើជាតំណាងរបស់ខ្លួន ដោយផ្តល់លិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរដែលបានចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុននោះ និងមានចុះកាលបរិច្ឆេទត្រឹមត្រូវទៅឱ្យក្រុមហ៊ុន។ លិខិតប្រគល់សិទ្ធិនេះអាចមានសុពលភាពជាក់លាក់តាមដែលបានកំណត់ដោយលិខិតប្រគល់សិទ្ធិនោះ ប៉ុន្តែមិនត្រូវមានសុពលភាពលើសពី ១ (មួយ) ឆ្នាំឡើយ។

### ២.៣.៨ កំណត់ហេតុ

(ក) កំណត់ហេតុទាំងឡាយ ឬសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលបានចេញដោយអនុលោមតាមប្រការ ២.៣.៩ ត្រូវរៀបរៀងក្រោមបញ្ជីមួយដែលមានចុះលេខទំព័រ និងចុះហត្ថលេខាសង្ខេប ឬ លើសន្លឹកក្រដាសដែលមានចុះលេខទំព័រ និងចុះហត្ថលេខាសង្ខេបស្របទៅតាមច្បាប់។

(ខ) សេចក្តីចម្លង ឬស្រង់នៃកំណត់ហេតុទាំងនេះ ឬ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ មានតម្លៃប្រើប្រាស់បានសម្រាប់គ្រប់គោលបំណងទាំងអស់ លុះត្រាតែមានការចុះហត្ថលេខា និងបញ្ជាក់ថាត្រឹមត្រូវពីប្រធានក្រុមប្រឹក្សាភិបាល។

### ២.៣.៩ សេចក្តីសម្រេចម្ចាស់ភាគហ៊ុនជាលាយលក្ខណ៍អក្សរ

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលមានចុះហត្ថលេខាដោយម្ចាស់ភាគហ៊ុនទាំងអស់ ដែលមានសិទ្ធិបោះឆ្នោតលើសេចក្តីសម្រេចនេះ នៅមហាសន្និបាតម្ចាស់ភាគហ៊ុន មានសុពលភាពដូចក្នុងករណីដែលសេចក្តីសម្រេចនេះ ត្រូវបានសម្រេចនៅក្នុងមហាសន្និបាតម្ចាស់ភាគហ៊ុនដែលបានកោះហៅ និងប្រព្រឹត្តឡើងស្របតាមប្រការ ២.៣ ខាងលើដែរ។

### ២.៤ កិច្ចសន្យារវាងក្រុមហ៊ុន និងម្ចាស់ភាគហ៊ុន ឬអភិបាល

(ក) កិច្ចសន្យាទាំងឡាយដែលធ្វើឡើងរវាងក្រុមហ៊ុន ជាមួយម្ចាស់ភាគហ៊ុន ឬអភិបាលរបស់ក្រុមហ៊ុន ឬសហព័ទ្ធ ឬដៃគូ ឬសាច់ញាតិរបស់ម្ចាស់ភាគហ៊ុន ឬអភិបាល ត្រូវតែដាក់ស្នើសុំសេចក្តីសម្រេចពីម្ចាស់ភាគហ៊ុន និងត្រូវដាក់តម្កល់នៅក្រសួងពាណិជ្ជកម្ម។

(ខ) ចំពោះកិច្ចសន្យាទាំងឡាយដែលធ្វើឡើងរវាងក្រុមហ៊ុន ជាមួយនឹងក្រុមហ៊ុនមួយដទៃទៀត ដែលម្ចាស់ភាគហ៊ុន ឬអភិបាលនៃក្រុមហ៊ុននោះ ក៏ជាម្ចាស់ភាគហ៊ុន ឬអភិបាលនៃក្រុមហ៊ុននេះដែរ ក៏ត្រូវតែដាក់ស្នើសុំសេចក្តីសម្រេចពីម្ចាស់ភាគហ៊ុនផងដែរ។

## ២.៥ សិទ្ធិទទួលបានព័ត៌មានរបស់ក្រុមហ៊ុន

(ក) នៅក្នុងពេលពិគ្រោះយោបល់របស់ម្ចាស់ភាគហ៊ុនទាំងឡាយ ទោះបីតាមលិខិតឆ្លងឆ្លើយក្តី ឬតាមមហាសន្និបាតក្តី ម្ចាស់ហ៊ុនម្នាក់ៗមានសិទ្ធិពិនិត្យឯកសារ និងព័ត៌មានផ្សេងៗដែលចាំបាច់ ដើម្បីអាចឱ្យម្ចាស់ភាគហ៊ុនអាចថ្លែងគំនិតបានដោយត្រឹមត្រូវ និងប្រកាន់យកសេចក្តីវិនិច្ឆ័យណាមួយ លើការចាត់ចែងក្រុមហ៊ុន។

(ខ) ម្យ៉ាងទៀត នៅរាល់ពេលណាក៏ដោយ ម្ចាស់ភាគហ៊ុនមានសិទ្ធិស្នើសុំឱ្យក្រុមហ៊ុនចេញសេចក្តីចម្លងនៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលមានបញ្ជាក់ការចម្លងត្រឹមត្រូវ និងមានតម្លៃប្រើប្រាស់តាមច្បាប់ជាធរមាន។

## ២.៦ សវនករ

(ក) ម្ចាស់ភាគហ៊ុន អាចតែងតាំងនូវ ឬ ដកហូតសវនករមួយរូប ឬច្រើនរូបដោយសេចក្តីសម្រេចរបស់សន្និបាតនៃម្ចាស់ភាគហ៊ុនដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់ ។

(ខ) សវនករត្រូវបានទទួលប្រាក់កម្រៃស្របទៅតាមច្បាប់។ សវនករ ត្រូវមានអំណាច និង កាតព្វកិច្ចរបស់ដូចដែលបានកំណត់ដោយច្បាប់ជាធរមាន។

## ២.៧ គណនីចរន្ត

(ក) ក្រៅពីការបណ្តាក់ដើមទុនដូចជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ម្ចាស់ភាគហ៊ុនម្នាក់ៗ អាចផ្ទេរ ឬដាក់ចូលទៅក្នុងមូលនិធិក្រុមហ៊ុន ក្នុងទម្រង់ជាគណនីចរន្ត នូវប្រាក់មួយចំនួនដែលចាំបាច់សម្រាប់ប្រតិបត្តិការក្រុមហ៊ុន។ ការផ្ទេរនេះ ត្រូវធ្វើឡើងសមមាត្រទៅតាមភាគរយរបស់ម្ចាស់ភាគហ៊ុននីមួយៗ ដែលបានរួមចំណែកក្នុងដើមទុនចុះបញ្ជី ដូចជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១។

(ខ) ប្រាក់ទាំងនេះអាចមានការប្រាក់ ឬគ្មានការប្រាក់ និងអាចត្រូវបានប្រើប្រាស់ ក្នុងលក្ខខណ្ឌដែលក្រុមប្រឹក្សាភិបាលកំណត់។

(គ) ការប្រាក់ដែលផ្តល់ឱ្យ ត្រូវចុះបញ្ចូលទៅក្នុងចំណាយទូទៅ និងអាចត្រូវបានពិនិត្យ ឡើងវិញជារៀងរាល់ឆ្នាំដោយម្ចាស់ភាគហ៊ុន។

(ឃ) ទឹកប្រាក់ដែលនៅក្នុងគណនីចរន្តទាំងឡាយ ត្រូវបានចាត់ទុកជាកម្ចីផ្តល់ដោយម្ចាស់ហ៊ុន ទៅក្នុងគណនីទាំងនេះ ហើយកម្ចីនេះត្រូវធ្វើឡើងស្របទៅតាមលក្ខខណ្ឌតម្រូវដោយច្បាប់ រួមបញ្ចូលទាំងច្បាប់

សារពើពន្ធផងដែរ។ ក្រុមហ៊ុនអាចវិញទាំងស្រុង ឬសងវិញជាផ្នែកៗ ក្រោយពីទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរ (១) ខែមុន។ ការសងនេះ ជាដំបូងត្រូវសងជូនទៅម្ចាស់ភាគហ៊ុននីមួយៗដែលក្រុមហ៊ុនជំពាក់ តាមចំនួនទឹកប្រាក់ដែលនៅជំពាក់ក្នុងគណនីចរន្ត។

(ង) ម្ចាស់ភាគហ៊ុនណាដែលចង់ដកយកវិញនូវប្រាក់ដែលខ្លួនបានដាក់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេល បី (៣) ខែជាមុន។

## ប្រការ ៣

## ភាគហ៊ុននៃក្រុមហ៊ុន – អនុប្បទាន និងការផ្ទេរភាគហ៊ុន

### ៣.១ សិទ្ធិ និងភាតព្វកិច្ចនៃភាគហ៊ុន

(ក) រាល់ភាគហ៊ុន មិនអាចត្រូវតំណាងដោយប័ណ្ណលក់ដូរសេរីលើទីផ្សារហ៊ុនបានឡើយ។ ភាគហ៊ុននីមួយៗ ផ្តល់ជូនកម្មសិទ្ធិករនូវសិទ្ធិស្មើគ្នាក្នុងប្រាក់ចំណេញ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន។

(ខ) ភាគហ៊ុនមួយ ត្រូវស្មើនឹងសម្លេងឆ្នោត មួយសម្លេងនៅក្នុងសេចក្តីសម្រេចរបស់ក្រុមហ៊ុន។

(គ) ម្ចាស់ភាគហ៊ុនទាំងឡាយទទួលខុសត្រូវ និងរ៉ាប់រងចំពោះបំណុល និងការខាតបង់របស់ក្រុមហ៊ុន ត្រឹមតែចំនួនទឹកប្រាក់ នៃដើមទុនផ្ទាល់របស់ខ្លួនដែលបានដាក់មកក្នុងក្រុមហ៊ុន។ លើសពីនេះរាល់ការអំពាវនាវសុំមូលនិធិអំពីសាធារណជន ត្រូវបានហាមឃាត់។

(ឃ) កម្មសិទ្ធិលើភាគហ៊ុនមួយ ផ្តល់នូវសិទ្ធិអំណាចពេញលេញក្នុងការចូលរួមជាម្ចាស់ភាគហ៊ុន ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន និងសិទ្ធិអំណាចចូលរួមក្នុងមហាសន្និបាតទាំងឡាយនៃក្រុមហ៊ុន។

(ង) ទោះបីនៅក្នុងដៃជនណាក៏ដោយ រាល់សិទ្ធិអំណាច និងភាតព្វកិច្ចដែលមានភ្ជាប់ជាមួយភាគហ៊ុនត្រូវរក្សាទុកដដែល។

(ច) អ្នកតំណាង ប្រតិសិទ្ធិ ទាយាទ និងម្ចាស់បំណុលផ្ទាល់ខ្លួនរបស់ម្ចាស់ភាគហ៊ុនម្នាក់ៗ ទោះបីក្នុងហេតុផលណាមួយក៏ដោយ មិនមានសិទ្ធិបង្ខំបិទទ្វារក្រុមហ៊ុន ឃុំឃាំងទ្រព្យសម្បត្តិ និងឯកសាររបស់ក្រុមហ៊ុន ឬក៏ជ្រៀតជ្រែកក្នុងកិច្ចការគ្រប់គ្រងក្រុមហ៊ុនឡើយ។ អ្នកទាំងនេះអនុវត្តសិទ្ធិរបស់ខ្លួន ដោយគោរពទៅតាមសេចក្តីសម្រេចនៃការជម្រះបញ្ជីសារពើភ័ណ្ឌ និងសេចក្តីសម្រេចនៃម្ចាស់ហ៊ុនទាំងអស់។

### ៣.២ អនុប្បទាន និងការផ្ទេរភាគហ៊ុន

(ក) ម្ចាស់ភាគហ៊ុនមានសិទ្ធិទិញបានមុននូវភាគហ៊ុនដែល បានដាក់សំណើលក់ ទៅតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុន តាមតម្លៃមួយដែលបានព្រមព្រៀងគ្នា ដោយភាគីទាំងពីរ។

(ខ) ប្រសិនបើម្ចាស់ភាគហ៊ុនណាម្នាក់ចង់លក់ ផ្ទេរ បញ្ចាំ ដាក់បន្ទុក ឬបញ្ចេញភាគហ៊ុន ម្ចាស់ភាគហ៊ុនផ្សេងទៀតមានសិទ្ធិបដិសេធមុន ដើម្បីទិញភាគហ៊ុននោះតាមតម្លៃសមស្របដែលភាគីទាំងពីរព្រមព្រៀង។

(គ) រាល់អនុប្បទានភាគហ៊ុន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ជាលិខិតរវាងឯកជន ឬជាលិខិតសារការី និងត្រូវតែមានការអនុម័តយល់ព្រមពីមហាសន្និបាតម្ចាស់ភាគហ៊ុនតំណាងដោយសម្លេងយ៉ាង

ហោចណាស់៧៥%(ចិតសិបប្រាំភាគរយ)នៃភាគហ៊ុនដែលមានសម្លេងបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុន ដែលមានវត្តមានក្នុងមហាសន្និបាតម្ចាស់ភាគហ៊ុន ឬដែលមានលិខិតប្រគល់សិទ្ធិ បានដាក់ផ្ញើជូនទៅប្រធានក្រុមប្រឹក្សាភិបាល យ៉ាងហោចណាស់ ៤៨ (សែសិបប្រាំបី) ម៉ោងមុនមហាសន្និបាត។

## ប្រការ ៤

## ការបែងចែកប្រាក់ចំណេញ – ការទូទាត់ភាគលាភ

### ៤.១ ការបែងចែកប្រាក់ចំណេញ

(ក) របាយការណ៍គណនីចំណូល ត្រូវគណនាដោយបូកសរុបចំណូលទាំងអស់ ហើយដកចេញរាល់ចំណាយទាំងឡាយនៃឆ្នាំសារពើពន្ធ បន្ទាប់ពីបានដកចេញនូវការរំលស់ទុន និងសំវិធានធនទាំងឡាយ។ របាយការណ៍ចំណូល ត្រូវបង្ហាញពីប្រាក់ចំណេញ ឬការខាតបង់នៃឆ្នាំសារពើពន្ធ។

(ខ) ប្រាក់ចំណេញនេះ ក្រោយពីបានកាត់ចេញនូវប្រាក់ខាតពីមុន ត្រូវដកចេញ ៥% (ប្រាំភាគរយ) សម្រាប់បង្កើតមូលនិធិបម្រុងស្របច្បាប់។ ការដកយក ៥% (ប្រាំភាគរយ) នេះ នឹងត្រូវបញ្ឈប់នៅពេលដែលមូលនិធិបម្រុងកើនដល់ចំនួន១០% (ដប់ភាគរយ)នៃដើមទុនក្រុមហ៊ុន។

(គ) ប្រាក់ចំណេញដែលអាចបែងចែកជូនម្ចាស់ភាគហ៊ុនបាន គឺប្រាក់ចំណេញដែលកាត់ចេញនូវប្រាក់ខាតពីមុន និងដកចេញនូវ ប្រាក់សម្រាប់មូលនិធិបម្រុងស្របច្បាប់។

(ឃ) ប្រាក់ចំណេញនេះ ត្រូវបានដាក់ជូនមហាសន្និបាតម្ចាស់ភាគហ៊ុនចាត់ចែង ហើយតាមសំណើរបស់ក្រុមប្រឹក្សាភិបាល អាចរក្សាទុកសម្រាប់ឆ្នាំក្រោយ ឬចាត់ចែងដាក់ទៅក្នុងមូលនិធិបម្រុងទូទៅ ឬពិសេស ឬបែងចែងជូនម្ចាស់ហ៊ុនទាំងឡាយ ទៅតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន។ ម៉្យាងទៀត មហាសន្និបាតម្ចាស់ភាគហ៊ុន អាចសម្រេច ធ្វើការបែងចែកនូវប្រាក់បម្រុងដែលអាចចាត់ចែងបាន ហើយសេចក្តីសម្រេចនេះ ត្រូវបញ្ជាក់ច្បាស់លាស់នូវប្រភេទនៃមូលនិធិបម្រុង ដែលត្រូវបានកាត់ដកយកប្រាក់បម្រុងមកបែងចែកនេះ។ ក៏ប៉ុន្តែភាគលាភ ត្រូវកាត់យកជាអាទិភាពពីប្រាក់ចំណេញដែលអាចបែងចែកបាននៃឆ្នាំសារពើពន្ធ។

### ៤.២ ការទូទាត់ភាគលាភ

ក្រោយពីបានពិនិត្យឃើញថា មានចំនួនប្រាក់គ្រប់គ្រាន់ក្នុងគណនីរបស់ក្រុមហ៊ុនសម្រាប់ធ្វើការបែងចែករួចហើយ ត្រូវធ្វើការចាត់ចែងបែងចែក និងទូទាត់ភាគលាភ។ ទម្រង់បែបបទនៃការបែងចែក ត្រូវកំណត់ដោយសន្និបាតនៃម្ចាស់ភាគហ៊ុន ឬបើពុំនោះទេ ដោយក្រុមប្រឹក្សាភិបាល។ ការទូទាត់ភាគលាភត្រូវតែធ្វើឡើងរៀងរាល់ឆ្នាំ។ អភិបាលក៏អាចចាត់ចែងប្រាក់បម្រុងពិសេសមួយភាគសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តពាណិជ្ជកម្មរបស់ក្រុមហ៊ុន ដោយប្រើប្រាស់មូលនិធិណាមួយរបស់ក្រុមហ៊ុនដែលមានសម្រាប់បែងចែកភាគលាភ។ ក្រុមហ៊ុនអាចបែងចែកភាគលាភជាសាច់ប្រាក់ ឬ ទ្រព្យសម្បត្តិបាន។

### ៤.៣ ការខាតបង់

ការខាតបង់ដែលពិនិត្យឃើញនៅក្នុងបញ្ជីគណនេយ្យ នឹងត្រូវទទួលយកដោយម្ចាស់ភាគហ៊ុន ទៅតាម សមាមាត្រនៃភាគហ៊ុនដែលម្ចាស់ហ៊ុនម្នាក់ៗមាន។ សល់ពីនេះនឹងត្រូវសងរំលោះ ដោយកាត់យកពីប្រាក់ចំណេញនៃឆ្នាំបន្តបន្ទាប់។

## ប្រការ ៥
## ឆ្នាំសារពើពន្ធនៃក្រុមហ៊ុន – បញ្ជីសារពើភ័ណ្ឌ

### ៥.១ ឆ្នាំសារពើពន្ធ

ឆ្នាំសារពើពន្ធចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ដោយលើកលែងឆ្នាំសារពើពន្ធដំបូង ដែលត្រូវចាប់ផ្តើមនាកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន និងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំបង្កើតក្រុមហ៊ុន។

### ៥.២ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច

ក្រុមប្រឹក្សាភិបាលត្រូវបង្ហាញ និងផ្ញើជូនទៅម្ចាស់ភាគហ៊ុនទាំងឡាយនូវរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួច យ៉ាងតិច២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ភាគហ៊ុនប្រចាំឆ្នាំ។ ការចុះហត្ថលេខាលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ត្រូវតែអនុលោមទៅតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមិនត្រូវបោះពុម្ព ឬបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុឡើយ លុះត្រាតែរបាយការណ៍ហិរញ្ញវត្ថុនោះត្រូវបានយល់ព្រមដោយក្រុមប្រឹក្សាភិបាល និងភ្ជាប់អមជាមួយដោយរបាយការណ៍សនវករ។

## ប្រការ ៦
## ការរំលាយក្រុមហ៊ុន – ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន – វិវាទ

### ៦.១ ការខាតបង់លើដើមទុន ការរំលាយក្រុមហ៊ុន

(ក) ក្នុងករណីដែលក្រុមហ៊ុនរងនូវការខាតបង់រហូតដល់ ៣/៤ (បីភាគបួន) នៃដើមទុនចុះបញ្ជី នោះក្រុមហ៊ុននឹងត្រូវរំលាយ ប្រសិនបើស្ថានភាពរបស់ក្រុមហ៊ុនមិនអាចស្តារឡើងវិញបានក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីការខាតបង់នេះ។

(ខ) ក្រុមហ៊ុនក៏អាចត្រូវបានរំលាយមុនការកំណត់បាន ដោយសេចក្តីសម្រេចពិសេសនៃម្ចាស់ភាគហ៊ុន ទោះបីជាមិនមានការខាតបង់ដើមទុនដូចខាងលើក៏ដោយ។

(គ) ក្រុមហ៊ុនក៏អាចត្រូវរំលាយបានដែរតាមផ្លូវតុលាការ ដោយមូលហេតុត្រឹមត្រូវ។

### ៦.២ ការរំលាយក្រុមហ៊ុន – ការជម្រះបញ្ជី

(ក) ក្នុងករណីមានការរំលាយក្រុមហ៊ុនដោយមូលហេតុណាមួយក្តី ក្រុមហ៊ុនត្រូវធ្វើការជម្រះបញ្ជី។

(ខ) ការរំលាយនេះ មានសុពលភាព និង អានុភាពចំពោះតតិយជន ចាប់ពីថ្ងៃដែលក្រុមហ៊ុនបានប្រកាសផ្សាយក្នុងបញ្ជីពាណិជ្ជកម្ម។

(គ) នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន នៅបន្តមានអត្ថិភាពសម្រាប់តម្រូវការនៃការជម្រះបញ្ជីរហូតដល់ពេលបិទការជម្រះបញ្ជីនេះ និងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម។ និទ្ទេសន៍ "ក្រុមហ៊ុនស្ថិតក្នុងការជម្រះបញ្ជី" ព្រមទាំងនាមនៃអ្នកជម្រះបញ្ជី ត្រូវតែមានចែងនៅលើរាល់លិខិតស្នាម និងឯកសារទាំងឡាយ ដែលផ្សាយចេញដោយក្រុមហ៊ុន។

(ឃ) ការជម្រះបញ្ជីត្រូវធ្វើឡើងដោយអ្នកជម្រះបញ្ជីម្នាក់ ឬច្រើននាក់ ដែលតែងតាំងដោយសេចក្ដីសម្រេច នៃម្ចាស់ភាគហ៊ុនតំណាងឱ្យ ៧៥% (ចិតសិបប្រាំភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ដែលមានវត្តមានក្នុងអង្គប្រជុំ។

(ង) ការជម្រះបញ្ជី ត្រូវអនុវត្តស្របទៅតាមច្បាប់។

## ៦.៣ មរណភាព – ការហាមឃាត់ – ធនក្ស័យនៃម្ចាស់ភាគហ៊ុនម្នាក់

មរណភាព អសមត្ថភាព ការហាមឃាត់ ធនក្ស័យរបស់ម្ចាស់ភាគហ៊ុនណាម្នាក់ដែលជារូបវន្តបុគ្គល ព្រមទាំងការកែទម្រង់ឡើងវិញ ឬការជម្រះបញ្ជីតាមផ្លូវតុលាការរបស់ម្ចាស់ភាគហ៊ុនមួយដែលជានីតិបុគ្គល មិនបណ្ដាលឱ្យក្រុមហ៊ុនរំលាយឡើយ។ ក៏ប៉ុន្តែ បើព្រឹត្តិការណ៍ណាមួយខាងលើ បានកើតមានឡើងចំពោះអភិបាល អភិបាលនេះត្រូវបានបញ្ឈប់ពីតំណែងជាអភិបាលភ្លាម។

## ៦.៤ ការផ្លាស់ប្ដូរទម្រង់ក្រុមហ៊ុន

(ក) ការផ្លាស់ប្ដូរទម្រង់ក្រុមហ៊ុន ទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចធ្វើបានដោយសេចក្ដីសម្រេចរបស់មហាសន្និបាតម្ចាស់ភាគហ៊ុនដែលមានសម្លេង៧៥% (ចិតសិបប្រាំភាគរយ) នៃភាគហ៊ុនដែលមានសម្លេងបោះឆ្នោតដែលមានវត្តមាននៅក្នុងសន្និបាតនោះ។

(ខ) រាល់សេចក្ដីសម្រេចផ្លាស់ប្ដូរទម្រង់ក្រុមហ៊ុន ត្រូវតែមានធ្វើជាមុននូវរបាយការណ៍លើស្ថានភាពរបស់ក្រុមហ៊ុន ទោះបីជាក្រុមហ៊ុនមិនទាន់មានសវនករនៅឡើយក៏ដោយ។

## ៦.៥ វិវាទ

រាល់បណ្ដឹងជំទាស់មុខ ឬវិវាទ ដែលអាចកើតឡើងរវាងម្ចាស់ភាគហ៊ុន និងម្ចាស់ភាគហ៊ុន ឬរវាងម្ចាស់ភាគហ៊ុននិងអភិបាល និងជាមួយ បុគ្គលិកក្រុមហ៊ុន នៅក្នុងថេរវេលាក្រុមហ៊ុន ឬនៅក្នុងរយៈពេលជម្រះបញ្ជី ត្រូវធ្វើការដោះស្រាយដោយការសម្រុះសម្រួលគ្នាក្នុងក្រុមហ៊ុន។ ក្នុងករណីមិនអាចសម្រុះសម្រួលគ្នាបានទេ ភាគីវិវាទអាចដាក់ពាក្យមកការិយាល័យទទួលពាក្យបណ្ដឹងនៃក្រសួងពាណិជ្ជកម្ម ឬទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈការផ្ទេកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងទៅតុលាការដែលមានសមត្ថកិច្ច។

# ប្រការ ៧

# ការគ្រប់គ្រងក្រុមហ៊ុន

## ៧.១ ការតែងតាំងអភិបាល

(ក) ក្រុមហ៊ុនត្រូវដឹកនាំ និងគ្រប់គ្រងដោយម្ចាស់ភាគហ៊ុន ឬ ដោយអភិបាល។ ក្នុងករណីដែលក្រុមហ៊ុននេះត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអភិបាល ឬក្រុមប្រឹក្សាភិបាល អភិបាលទាំងនេះត្រូវទទួលបាន ប្រាក់បៀវត្ស ឬ ប្រាក់រង្វាន់ តាមការព្រមព្រៀងរវាងក្រុមហ៊ុន និងអភិបាល។

(ខ) ក្រុមហ៊ុនត្រូវដឹកនាំ និងគ្រប់គ្រងដោយអភិបាល ដូចជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃលក្ខន្តិកៈក្រុមហ៊ុននេះ។

(គ) អាណត្តិរបស់អភិបាលអាចមានរយៈពេលកំណត់ ឬមិនកំណត់។

(ឃ) អភិបាលអាចត្រូវបានជ្រើសតាំងឡើងវិញក្នុងករណីចាំបាច់ និងសមស្រប។

(ង) អភិបាលត្រូវ ជ្រើសតាំងតាមសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

(ច) អភិបាលអាចលាលែងពីតំណែងខ្លួនបាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនយ៉ាងតិចរយៈពេល ៣ (បី) ខែ អំពីការលាលែងនេះ តាមលិខិតប្រៃសណីយ៍ ទៅម្ចាស់ភាគហ៊ុន ដោយមានលិខិតបញ្ជាក់ពីការទទួលបានការជូនដំណឹងនោះផងដែរ ។

(ឆ) អភិបាលអាចត្រូវបានដកហូតពីតំណែងបាន ដោយសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

(ជ) មុខតំណែងជាអភិបាល រង្វាន់ និងប្រាក់បៀវត្សរបស់អភិបាល ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន។

## ៧.២ ការជ្រើសតាំងប្រធានក្រុមប្រឹក្សាភិបាល

អភិបាលអាចជ្រើសតាំងប្រធានក្រុមប្រឹក្សាភិបាលពីក្នុងចំណោមសមាជិករបស់ខ្លួន និងកំណត់រយៈពេលដែល ប្រធានក្រុមប្រឹក្សាភិបាលនោះនឹងកាន់តំណែងរបស់ខ្លួន។ នៅក្នុងសន្និបាតនីមួយៗ ប្រសិនបើប្រធានក្រុមប្រឹក្សាភិបាលមិនមានវត្តមានក្នុងកំឡុងពេល ១០ (ដប់) នាទី បន្ទាប់ពីពេលវេលាកំណត់សម្រាប់បើកសន្និបាត អភិបាលដែលមានវត្តមានក្នុងសន្និបាតនោះ អាចជ្រើសរើសសមាជិកមួយរូបរបស់ពួកគេឱ្យធ្វើជាប្រធានក្រុមប្រឹក្សាភិបាលនៅក្នុងសន្និបាតនោះបាន។ ប្រធានក្រុមប្រឹក្សាភិបាលនឹងមិនមែនជាប្រធានក្រុមប្រឹក្សាភិបាលទៀតទេ ប្រសិនបើប្រធានក្រុមប្រឹក្សាភិបាលនោះលែងជាអភិបាលក្រុមហ៊ុន។

## ៧.៣ អំណាចរបស់អភិបាល ប្រធានក្រុមប្រឹក្សាភិបាល

### ៧.៣.១-អភិបាល

(ក) អភិបាលត្រូវមានសិទ្ធិអំណាចពេញលេញ ក្នុងការគ្រប់គ្រងការងាររបស់ក្រុមហ៊ុន លើកលែងតែមានសេចក្តីសម្រេចម្ចាស់ភាគហ៊ុនដែលអនុញ្ញាតឱ្យធ្វើសកម្មភាពណាមួយ និង/ឬដាក់កំហិតលើអំណាចរបស់អភិបាល ឬលើកលែងចំពោះសកម្មភាព ឬបញ្ហាដែលច្បាប់ ឬលក្ខន្តិកៈក្រុមហ៊ុននេះ តម្រូវឱ្យមានការសម្រេច ឬព្រមព្រៀងដោយម្ចាស់ភាគហ៊ុន។

(ខ) អភិបាលអាចផ្តល់អំណាច ឬលិខិតប្រគល់សិទ្ធិជូនកាន់បុគ្គលណាម្នាក់ ឱ្យចុះហត្ថលេខា ប្រគល់ជូន និង អនុវត្តទម្រង់បែបបទផ្លូវការទាំងឡាយណាដែលសំខាន់ បន្ទាប់បន្សំ ឬ ជាបែបបទរដ្ឋបាលសម្រាប់ការងារទាំងឡាយណា ដែលទទួលបានការយល់ស្របពីអភិបាល និង ពីម្ចាស់ភាគហ៊ុន ប្រសិនបើមានការតម្រូវណាមួយ។

(គ) អភិបាលត្រូវមានសិទ្ធិ និងអំណាចពេញលេញ ក្នុងការចុះហត្ថលេខាលើសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់អភិបាល និងសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ ឬកំណត់ហេតុអង្គប្រជុំដែលអាចមានឯកសារមួយចំនួន (ឬឯកសារចម្លង) ក្នុងទម្រង់ដូចគ្នា ដែលឯកសារនីមួយៗត្រូវបានចុះហត្ថលេខាដោយអភិបាលមួយរូបឬច្រើនរូប។ បើក្រុមហ៊ុនមានអភិបាលតែមួយរូប អភិបាលនោះអាចចេញសេចក្ដីសម្រេចដោយកត់កំណត់ហេតុ ហើយចុះហត្ថលេខាលើកំណត់ហេតុនោះ។ ហើយហត្ថលេខានោះ ត្រូវមានសុពលភាព និងអានុភាពដូចត្រូវបានសម្រេចនៅក្នុងអង្គប្រជុំផងដែរ។

(ឃ) អភិបាលក៏ត្រូវមានអំណាចដូចខាងក្រោមផងដែរៈ

(១) តែងតាំង និងដកហូតតំណែងរបស់បុគ្គលិកទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់បុគ្គលិកទាំងនោះ។

(២) កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់បុគ្គលិកទាំងនោះ។

(៣) កម្រិតប្រាក់បៀវត្ស ឬប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនទៅម្ចាស់ភាគហ៊ុនដើម្បីសុំសេចក្ដីសម្រេច។

(៤) ចេញសញ្ញាប័ណ្ណ លិខិតស្នាមដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈជាមូលដ្ឋាន និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងនោះ។

(៥) ស្នើសុំការយល់ស្របពីម្ចាស់ភាគហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ របស់ក្រុមហ៊ុន។

(៦) ស្នើសុំការយល់ស្របពីម្ចាស់ភាគហ៊ុន លើកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និង បុគ្គលផ្សេងណាមួយ។

(៧) ស្នើសុំការយល់ស្របពីម្ចាស់ភាគហ៊ុន ដើម្បីលក់ទ្រព្យក្រុមហ៊ុនទាំងអស់ ឬមួយភាគ។

(៨) ស្នើសុំការយល់ស្របពីម្ចាស់ភាគហ៊ុនដើម្បីរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន។

(៩) ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និង តាមលក្ខខណ្ឌនៃទូទាត់របស់ភាគហ៊ុន ប្រភេទនីមួយៗដែលមានសិទ្ធិទទួលភាគលាភ។

(១០) ខ្ចីប្រាក់។

(១១) បោះចេញ បោះចេញសាជាថ្មី ឬ លក់មូលបត្ររបស់ក្រុមហ៊ុន។

(១២) ផ្ដល់ការធានាក្នុងនាមក្រុមហ៊ុន។

(១៣) ចុះបញ្ជីហ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ ធានា ឬបើមិនដូច្នេះទេ បង្កើតសិទ្ធិប្រាតិភោគលើទ្រព្យទាំងអស់ ឬ ទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុន ដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន។

(១៤) រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗ និងដាក់លទ្ធផលប្រចាំឆ្នាំជូនម្ចាស់ភាគហ៊ុន។

(ង) មូលប្បទានប័ត្រ (cheques) ប័ណ្ណកំណត់សន្យា រូបិយាណត្តិ និងឧបករណ៍ដែលអាចជួញដូរបានដទៃទៀត និងវិក្កយបត្រទទួលប្រាក់ទាំងឡាយ ដែលបានទូទាត់មកក្រុមហ៊ុន ត្រូវតែមានចុះហត្ថលេខាទទួល ចារ ដោយអភិបាលដែលពាក់ព័ន្ធ ឬ នៅតាមវិធីផ្សេងៗ ដែលអភិបាលកំណត់។

### ៧.៣.២ ប្រធានក្រុមប្រឹក្សាភិបាល

(ក) នៅក្នុងទំនាក់ទំនងជាមួយតតិយជន ប្រធានក្រុមប្រឹក្សាភិបាលត្រូវបានប្រគល់អំណាចជូនយ៉ាងទូលំទូលាយដើម្បីធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុននៅគ្រប់កាលៈទេសៈ។

(ខ) ប្រធានក្រុមប្រឹក្សាភិបាលមានអំណាច ជាតំណាងឱ្យក្រុមហ៊ុន និងចុះហត្ថលេខាលើរាល់ឯកសារដែលស្ថិតក្នុងរង្វង់ក្របខ័ណ្ឌនៃកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ហើយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះ តតិយជន។ ក្នុងការករណីដែលប្រើប្រាស់អំណាច នៅក្នុងប្រការណាមួយដែលផ្ទុយពីកិច្ចការដែលរៀបរាប់ខាងលើ ហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកជាមោឃៈ ហើយអ្នកប្រព្រឹត្តល្មើសនេះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបច្ច័យទាំងឡាយ ដែលមានកើតឡើងដោយសារឥរិយាបថទាំងនេះ ហើយអាចត្រូវបានដកហូតពីមុខតំណែងចេញពីប្រធានក្រុមប្រឹក្សាភិបាល។

(គ) ការចុះកិច្ចសន្យាដោយប្រធានក្រុមប្រឹក្សាភិបាលជាមួយតតិយជន លើកិច្ចការទាំងឡាយដែលស្ថិតនៅក្រៅកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ក៏បណ្តាលឱ្យក្រុមហ៊ុនជាប់កាតព្វកិច្ចចំពោះកិច្ចសន្យានោះដែរ។ ប៉ុន្តែក្នុងករណីនេះ ក្រុមហ៊ុនក៏អាចប្រកែកមិនទទួលខុសត្រូវបានដែរ ដោយរកភស្តុតាងបញ្ជាក់ថា តតិយជននោះ បានដឹងដោយច្បាស់ថា ប្រធានក្រុមប្រឹក្សាភិបាល បានចុះកិច្ចសន្យានោះហួសពីកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ជាក់ថា តតិយជននោះមិនអាចដោះសារថាខ្លួនមិនបានដឹងពីស្ថានភាពនេះ។ ដើម្បីរួចផុតពីការទទួលខុសត្រូវខាងលើ ក្រុមហ៊ុនមិនអាចយកការចុះផ្សាយសម្រង់លក្ខន្តិកៈក្រុមហ៊ុនក្នុងសារព័ត៌មាន មកធ្វើជាភស្តុតាងសម្រាប់ជាសម្អាងបានទេ។ ដូច្នេះនៅពេលកើតវិវាទបែប នេះត្រូវតែផ្តល់នូវឯកសារ សម្អាងនានាដូចជា លិខិតសម្អាងជាលាយលក្ខណ៍អក្សរ វត្ថុតាងផ្សេងៗ ។ល។

(ឃ) នៅក្នុងទំនាក់ទំនងជាមួយម្ចាស់ភាគហ៊ុន ប្រធានក្រុមប្រឹក្សាភិបាលអាចធ្វើរាល់កិច្ចការ សម្រាប់ជាផលប្រយោជន៍របស់ក្រុមហ៊ុន។ ក៏ប៉ុន្តែ កិច្ចការខ្លះដូចមានបញ្ជាក់ខាងក្រោមនេះ ត្រូវតែមានការអនុញ្ញាតដោយសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុន រួមមានការទិញ ការលក់ ការដោះដូរអចលនទ្រព្យ ឬមូលនិធិពាណិជ្ជកម្មរបស់ក្រុមហ៊ុន ការចុះកិច្ចសន្យាខ្ចីបុលក្នុងនាមក្រុមហ៊ុន ការខ្ចីឥណទានពីធនាគារ ឬតតិយជន ការធ្វើហ៊ីប៉ូតែកលើសង្ហារឹមភ័ណ្ឌរបស់ក្រុមហ៊ុន ឬការបញ្ចាំមូលនិធិពាណិជ្ជកម្ម ឬការចូលរួមសហការក្នុងការបង្កើតក្រុមហ៊ុននានា ការកែប្រែលក្ខន្តិកៈ។

(ង) តាមរយៈលិខិតស្នាមជាលាយលក្ខណ៍អក្សរ ក្រុមប្រឹក្សាភិបាលអាចតែងតាំង គណៈកម្មាធិការណាមួយឱ្យទទួលចាត់ចែងនូវការងារណាមួយ ឬភារកិច្ចមួយចំនួន ជំនួសខ្លួន និងក្រោមការត្រួតពិនិត្យរបស់ខ្លួនផ្ទាល់។

### ៧.៤ សន្និបាតក្រុមប្រឹក្សាភិបាល

(ក) សន្និបាតក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងយ៉ាងតិច រាល់៣(បី)ខែ ម្តង។

(ខ) ប្រធានក្រុមប្រឹក្សាភិបាល ឬក្នុងករណីបន្ទាន់ ១/៣ នៃអភិបាល អាចកោះប្រជុំសន្និបាតក្រុមប្រឹក្សាភិបាលបានដោយ ផ្ញើលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរទៅកាន់អភិបាលទាំងអស់ យ៉ាងហោចណាស់ ១៤ (ដប់បួន) ថ្ងៃមុនថ្ងៃប្រជុំ។

(គ) លិខិតអញ្ជើញសម្រាប់អភិបាល ត្រូវតែផ្ញើតាមប្រៃសណីយ៍ ឬអ្នកនាំសារផ្ទាល់របស់ក្រុមហ៊ុន ឬទូរសារ ឬតាមរយៈមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចនានា។

(ឃ) លិខិតអញ្ជើញត្រូវកំណត់យ៉ាងច្បាស់ពីទីតាំង កាលបរិច្ឆេទ និងពេលវេលានៃសន្និបាត និងចែងអំពីរបៀបវារៈសម្រាប់ការពិភាក្សា និងសម្រេចផងដែរ។

(ង) អភិបាលទាំងអស់ត្រូវរក្សាអាសយដ្ឋានជាក់លាក់បច្ចុប្បន្ននិងពេញលេញរបស់ខ្លួន និងព័ត៌មានទាក់ទងលំអិតនៅទីស្នាក់ការរបស់ក្រុមហ៊ុន។ ពុំដូច្នេះទេ អភិបាលនោះ មិនអាចប្ដឹងតវ៉ាបានឡើយ ប្រសិនបើ ខ្លួនមិនបានទទួលសេចក្ដីជូនដំណឹងពីកិច្ចប្រជុំសន្និបាតណាមួយ។

## ៧.៥ កូរ៉ុមសម្រាប់សន្និបាតអភិបាល

(ក) កូរ៉ុមរបស់សន្និបាតអភិបាលគឺត្រូវតែជាចំនួនភាគច្រើននៃចំនួនអភិបាលសរុប។

(ខ) អភិបាលម្នាក់អាចប្រគល់សិទ្ធិជូនអភិបាលម្នាក់ទៀតធ្វើជាតំណាងរបស់ខ្លួនក្នុងការចូលរួម និងបោះឆ្នោតនៅក្នុងសន្និបាត ដោយមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខាដោយអភិបាលដែលខ្លួនធ្វើតំណាងឲ្យ។

## ៧.៦ ទម្រង់នៃសន្និបាត

សន្និបាតនៃអភិបាល ដែលធ្វើឡើងតាមរយៈទូរស័ព្ទ ឬមធ្យោបាយអេឡិចត្រូនិចផ្សេងៗ រួមទាំងការទាក់ទងតាមសម្លេង ឬសម្លេងនិងរូបភាព ទោះបីជាអភិបាលមិនមានវត្តមាននៅកន្លែងតែមួយ នាពេលប្រជុំក៏ដោយ ក៏ត្រូវចាត់ទុកថាមានសុពលភាព និងមានអានុភាពដូចក្នុងករណីដែលសេចក្ដីសម្រេចបានសម្រេចនៅក្នុងមហាសន្និបាតក្រុមប្រឹក្សាភិបាលដែលមានកោះប្រជុំត្រឹមត្រូវដែរ។

## ៧.៧ សេចក្ដីសម្រេចរបស់អភិបាល

(ក) ដោយស្របតាមលក្ខន្តិកៈក្រុមហ៊ុននេះ ឬការតម្រូវការតាមច្បាប់ សេចក្ដីសម្រេចដែលសម្រេចនៅ សន្និបាតណាមួយនៃក្រុមប្រឹក្សាភិបាល ត្រូវតែធ្វើឡើងតាមសម្លេងភាគច្រើននៃអភិបាលដែលមានវត្តមាននៅក្នុងសន្និបាតនោះ។ សេចក្ដីសម្រេចដោយសម្លេងភាគច្រើននៃអភិបាល គឺត្រូវបានចាត់ទុកថាជាសេចក្ដីសម្រេចរបស់អភិបាល។

(ខ) អភិបាលមិនត្រូវបោះឆ្នោតចំពោះប្រតិបត្តិការណាមួយ ឬការស្នើប្រតិបត្តិការណាមួយ ដែលអភិបាលនោះទទួលបានផលប្រយោជន៍ ឬទាក់ទងទៅនឹងបញ្ហាណាមួយដែលកើតឡើងពីប្រតិបត្តិការនោះ ឬការស្នើប្រតិបត្តិការនោះឡើយ។ ប្រសិនបើអភិបាលនោះបានបោះឆ្នោតទៅលើប្រតិបត្តិការណាមួយ ឬការស្នើប្រតិបត្តិការណាមួយ ដូចដែលបានបញ្ជាក់ខាងលើ សម្លេងបោះឆ្នោតរបស់អភិបាលនោះមិនត្រូវបានរាប់នោះទេ។

## ៧.៨ សេចក្ដីសម្រេចរបស់អភិបាលជាលាយលក្ខណ៍អក្សរ

(ក) សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលត្រូវបានចុះហត្ថលេខាដោយអភិបាលទាំងអស់ ដែលមានសិទ្ធិ ទទួលបានសេចក្តីជូនដំណឹងអំពីសន្និបាតក្រុមប្រឹក្សាភិបាល គឺមានសុពលភាព និង អានុភាពដូចដែលសេចក្តីសម្រេចដែលបានសម្រេចនៅក្នុងសន្និបាតក្រុមប្រឹក្សាភិបាល ដែលបានកោះហៅនិងបើកការប្រជុំយ៉ាងត្រឹមត្រូវផងដែរ។

(ខ) សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរណាមួយ ស្របតាមកថាខណ្ឌ (ក) ខាងលើ អាចធ្វើឡើងជាឯកសារច្រើនក្នុងទម្រង់ដូចគ្នា ដែលឯកសារនីមួយៗត្រូវបានចុះហត្ថលេខាដោយអភិបាលមួយរូបឬច្រើនរូប។

(គ) បើក្រុមហ៊ុនមានអភិបាលតែមួយរូប អភិបាលនោះអាចចេញសេចក្តីសម្រេចដោយកត់ក្នុងកំណត់ហេតុ ហើយចុះហត្ថលេខាលើកំណត់ហេតុនោះ។

## ៧.៩ កំណត់ហេតុ

អភិបាលត្រូវចាត់ចែងរៀបចំ និងចុះបញ្ជី សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សាភិបាល និងម្ចាស់ហ៊ុន កំណត់ហេតុនៃសន្និបាត ដំណើរការនៃមហាសន្និបាតម្ចាស់ហ៊ុន និង សន្និបាតក្រុមប្រឹក្សាភិបាល ទៅក្នុងកំណត់ហេតុក្រុមហ៊ុន ដោយមានបញ្ជាក់នូវទីកន្លែង កាលបរិច្ឆេទ និង ពេលវេលានៃសន្និបាត វត្តមានរបស់អភិបាល និង ម្ចាស់ហ៊ុន។

## ប្រការ ៨

## នីតិបុគ្គលិកលក្ខណៈ – ការចុះបញ្ជីពាណិជ្ជកម្ម – ការចុះផ្សាយ – សោហ៊ុយ

(ក) ក្រុមហ៊ុនមាននីតិបុគ្គលិកលក្ខណៈពេញលេញ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីពាណិជ្ជកម្ម។

(ខ) ដើម្បីទទួលបានការចុះបញ្ជីពាណិជ្ជកម្មនេះ ស្ថាបនិក ឬអភិបាល ឬអាណត្តិគាហកដែលមាន សមត្ថភាពតាមផ្លូវច្បាប់ ត្រូវចុះឈ្មោះ និងតម្កល់ទុកលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មតាមការបញ្ញត្តិនៃច្បាប់។

(គ) រាល់សិទ្ធិពេញលេញត្រូវបានប្រគល់ជូនស្ថាបនិក ឬអភិបាល ឬអាណត្តិគាហកដែលមាន សមត្ថភាពតាមផ្លូវច្បាប់ ដើម្បីបំពេញទម្រង់ការនៃការផ្សព្វផ្សាយដែលច្បាប់បានបញ្ញត្តិ និងជាពិសេស ដើម្បីចុះហត្ថលេខាលើសេចក្តីប្រកាសដែលចុះផ្សាយក្នុងសារព័ត៌មាន។

(ឃ) រាល់សោហ៊ុយចំណាយ ពន្ធអាករផ្សេងៗ និងកម្រៃនានាដែលកើតមានមុនពេលក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្ម ត្រូវជាបន្ទុករបស់ម្ចាស់ភាគហ៊ុនទាំងអស់គ្នា ទៅតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន។ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះ រាល់សោហ៊ុយ ចំណាយទាំងអស់នេះ នឹងត្រូវទទួលបន្ទុកដោយក្រុមហ៊ុន ដែលនឹងធ្វើការរំលស់នៅមុនពេលបែងចែកប្រាក់ចំណេញ និងយ៉ាងយូរបំផុតត្រូវរំលស់ឱ្យអស់នៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ។

# ឧបសម្ព័ន្ធទី១

## ព័ត៌មានក្រុមហ៊ុន

- នាមករណ៍ក្រុមហ៊ុន (ជាភាសាខ្មែរ) ៖
- នាមករណ៍ក្រុមហ៊ុន (ជាភាសាអង់គ្លេស) ៖
- ទ្រង់ទ្រាយ ៖
- កម្មវត្ថុអាជីវកម្ម (លេខសម្គាល់ និងការពណ៌នារបស់កម្មវត្ថុអាជីវកម្ម)៖
- អាសយដ្ឋានចុះបញ្ជី ៖
- ដើមទុនចុះបញ្ជី និងតម្លៃចារឹកលើបណ្ណភាគហ៊ុន៖
- ព័ត៌មានម្ចាស់ហ៊ុន៖

| ឈ្មោះ | អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន | ចំនួនហ៊ុន និង ភាគរយនៃភាគហ៊ុន | ហត្ថលេខា (បានអាន និងយល់ព្រម) |
|---|---|---|---|
| 1. | | | |
| 2. | | | |

- ព័ត៌មានអភិបាល៖

| ឈ្មោះ | អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន | តួនាទី | ហត្ថលេខា (បានអាន និងយល់ព្រម) |
|---|---|---|---|
| 1. | | | |
| 2. | | | |
| 3. | | | |

- តារាងឈ្មោះម្ចាស់ភាគហ៊ុន ឬអភិបាល មានសិទ្ធិតែងតាំង នាយកប្រតិបត្តិ ឬប្រធានសាខា ឬបើក និងប្រើប្រាស់គណនីធនាគារក្រុមហ៊ុន៖

| ឈ្មោះ | អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន | តួនាទី | ហត្ថលេខា (បានអាន និងយល់ព្រម) |
|---|---|---|---|
| ១. | | | |
| ២. | | | |
| ៣. | | | |

**ឧបសម្ព័ន្ធទី៣៖** គំរូសេចក្តីប្រកាសពីបំណងរំលាយ និងពាក្យស្នើសុំ
ភ្ជាប់នឹងប្រកាសលេខ ០៤៤ ព.ណ.ន.សហព.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៦
ស្តីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម ដំណាក់កាលទី២

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ក.ក.ក ៦.ក**

KOR.KOR.KOR CO., LTD.

**សូមគោរពជូន**

**លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ** ៖ សំណើសុំប្រកាសពីបំណាងជម្រះបញ្ជីនិងលុបឈ្មោះក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្ម ។

**យោង** ៖ វិញ្ញាបនបត្រមានអត្តលេខចុះបញ្ជីពាណិជ្ជកម្មលេខ 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ

តបតាមកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមជម្រាប **លោកជំទាវរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយសារទីផ្សារពុំអំណោយផល ហេតុនេះយើងខ្ញុំក៏បានស្នើសុំបិទក្រុមហ៊ុនដោយគោរពតាមបែបបទ និងនីតិវិធីច្បាប់ជាធរមាន។យើងខ្ញុំបានស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ ហើយទទួលបានលិខិតបញ្ជាក់ស្តីពីការបិទក្រុមហ៊ុនជាស្ថាពររួចរាល់ផងដែរ។ ដើម្បីអាចបន្តនីតិវិធីបិទក្រុមហ៊ុននេះ យើងខ្ញុំសុំធ្វើការប្រកាសពីការជម្រះបញ្ជី ដើម្បីរំលាយ និងលុបឈ្មោះក្រុមហ៊ុនរបស់យើងខ្ញុំពីបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មជាស្ថាពរ។

អាស្រ័យហេតុនេះ សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច លើការប្រកាសពីបំណាងជម្រះបញ្ជីនិងលុបឈ្មោះក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនយើងខ្ញុំដោយក្តីអនុគ្រោះ ។

សូម **លោកជំទាវ រដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ថ្ងៃទី ខែ ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល**

( ហត្ថលេខា និង ត្រា )

លោក **ក**

គំរូលិខិត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

នាមករណ៍ក្រុមហ៊ុន : **ក.ក.ក ៦.ក**

**KOR.KOR.KOR CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ

## សេចក្តីសម្រេចសមូហភាព

អង្គប្រជុំក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **ក.ក.ក ៦.ក**. **KOR.KOR.KOR CO., LTD.** ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋាននៅលេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**សមាសភាពក្រុមប្រឹក្សាភិបាល៖**

- លោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- លោក **ខ** ជាអភិបាល កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន

## សេចក្តីសម្រេចសមូហភាព

១. សម្រេចប្រកាសពីគោលបំណងចម្រុះបញ្ជី

២. សម្រេចប្រកាសពីគោលបំណងរំលាយ និងលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម។

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃទី ខែ ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល**

( ហត្ថលេខា និង ត្រា )

**បានអាន និង យល់ព្រម**

(ហត្ថលេខា)

**ក**

**ខ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

**ក្រុមហ៊ុន ក.ក.ក ៦.ក**

KKOR.KOR.KOR CO., LTD.

**សូមគោរពជូន**

**លោកជំទាវរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ** ៖ សំណើសុំរំលាយនិងលុបឈ្មោះក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

**យោង** ៖ -វិញ្ញាបនបត្រមានអត្តលេខចុះបញ្ជីពាណិជ្ជកម្មលេខ 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ

-លិខិតបញ្ជាក់ស្ថានភាពសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

តបតាមកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមជម្រាប **លោកជំទាវរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយសារទីផ្សារពុំអំណោយផល ហេតុនេះយើងខ្ញុំក៏បានស្នើសុំបិទក្រុមហ៊ុនដោយគោរពតាមបែបបទ និងនីតិវិធីច្បាប់ជាធរមាន។យើងខ្ញុំបានស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ ហើយទទួលបានលិខិតបញ្ជាក់ស្តីពីការបិទក្រុមហ៊ុនជាស្ថាពររួចរាល់ផងដែរ។ ដើម្បីអាចបន្តនីតិវិធីបិទក្រុមហ៊ុននេះ យើងខ្ញុំសុំរំលាយនិងលុបឈ្មោះក្រុមហ៊ុនរបស់យើងខ្ញុំពីបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មជាស្ថាពរ។

អាស្រ័យហេតុនេះ សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច លើការរំលាយនិងលុបឈ្មោះក្រុមហ៊ុនពីបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនយើងខ្ញុំដោយក្តីអនុគ្រោះ ។

សូម **លោកជំទាវ រដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ថ្ងៃទី ខែ ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល**

( ហត្ថលេខា និង ត្រា )

លោក **ក**

គំរូ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

នាមករណ៍ក្រុមហ៊ុន : **ក.ក.ក ៦.ក**

**KOR.KOR.KOR CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ

## កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចសម្ព័ហភាព

ឆ្នាំពីរពាន់ ខែ ថ្ងៃទី វេលាម៉ោងប្រាំបីព្រឹក នៅទីស្នាក់ការក្រុម **ក.ក.ក ៦.ក KOR.KOR.KOR CO., LTD.** ដែលមានអាសយដ្ឋាន លេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ មានបើកអង្គប្រជុំវិសាមញ្ញមួយក្រោមអធិបតីភាព របស់ លោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ជាប្រធានអង្គប្រជុំ ។

### អញ្ជើញចូលរួមក្នុងអង្គប្រជុំមាន ៖

- លោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- លោក **ខ** ជាអភិបាល កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន

### របៀបវារៈនៃអង្គប្រជុំ ៖

១- ការរំលាយក្រុមហ៊ុន និងលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម
២- ការប្រគល់សិទ្ធជូនលោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាលក្នុងការជម្រះបញ្ជី
៣- ការតែងតាំងសវនករ

### លទ្ធផលនៃអង្គប្រជុំ ៖

ជាកិច្ចចាប់ផ្តើម លោកស្រីប្រធានអង្គប្រជុំបានធ្វើការកត់សំគាល់នូវចំនួនសមាជិកម្ចាស់ហ៊ុនមានវត្តមានក្នុងអង្គប្រជុំមានចំនួន ០២ រូប ដែលរួមមានកាន់កាប់ភាគហ៊ុនចំនួន ១០០០ ភាគហ៊ុនលើភាគហ៊ុនសរុប ១០០០ ភាគហ៊ុនរបស់ក្រុមហ៊ុន ។ ចំនួនសមាជិកភាគហ៊ុនវត្តមាននេះ តំណាងឲ្យចំនួនលើសពីពាក់កណ្តាល +1 នៃដើមទុនទាំងអស់របស់ក្រុមហ៊ុន ដែលជាកូរ៉ុមគ្រប់គ្រាន់សម្រាប់ធ្វើសេចក្តីសម្រេចបានដោយស្របច្បាប់ ។

### អង្គប្រជុំសម្រេចដូចតទៅ ៖

១ - យល់ព្រមលើការរំលាយក្រុមហ៊ុននិងលុបឈ្មោះក្រុមហ៊ុន **ក.ក.ក ៦.ក KOR.KOR.KOR CO., LTD.** ចេញពីបញ្ជីពាណិជ្ជកម្ម មុនកាលកំណត់ដោយមូលហេតុទីផ្សារពុំអំណោយផលចំពោះក្រុមហ៊ុន ។

២ - យល់ព្រមលើប្រគល់សិទ្ធជូន លោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាលក្នុងការជម្រះបញ្ជី និងចេញសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុនព្រមទាំងបំពេញបែបបទលិខិតស្នាមក្នុងការផ្សាយជាសាធារណៈ និងលុបឈ្មោះ ក្រុមហ៊ុនចេញពី បញ្ជីពាណិជ្ជកម្ម ស្របទៅតាមបទបញ្ញត្តិនៃច្បាប់។

៣ - យល់ព្រមលើការតែងតាំង លោក **ច** "តតិយជន" ជាសវនករ។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោងដប់មួយព្រឹក នាថ្ងៃដដែល ។

ថ្ងៃទី ខែ ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល**

( ហត្ថលេខា និង ត្រា )

**ក**

**បានអាន និង យល់ព្រម**

(ហត្ថលេខា)

**ខ**

**បានអាន និង យល់ព្រម**

**សវនករ**

**ច**

គំរូពាក្យសុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

**ក្រុមហ៊ុន ក.ក.ក ៦.ក**
**KOR.KOR.KOR CO., LTD.**

អាសយដ្ឋាន៖ លេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ

## <u>លិខិតតែងតាំងសវនករ</u>

ខ្ញុំឈ្មោះ **ក** ប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន **ក.ក.ក ៦.ក KOR.KOR.KOR CO., LTD.** បាន ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មក្រោមអត្តលេខ 0000000000 ចុះថ្ងៃទី ខែ ឆ្នាំ និងបានចុះ បញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារក្រោមអត្តលេខ និងមានទីស្នាក់ការ ក្រុមហ៊ុន ស្ថិតលេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

## <u>សូមធ្វើការតែងតាំង</u>

ឈ្មោះ **ប** ភេទ សញ្ជាតិ កាន់អត្តសញ្ញាណប័ណ្ណលេខ ចុះថ្ងៃទី ជាអ្នកតំណាងស្របច្បាប់ និងតែងតាំងជាសវនកររបស់ក្រុមហ៊ុនដើម្បីធ្វើការជំរះបញ្ជីដើម្បីរំលាយ ក្រុមហ៊ុន និងលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីរបស់ក្រសួងពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ សូមភាគីដែលពាក់ព័ន្ធមេត្តាទទួលស្គាល់អ្នកតំណាង និងជាសវនកររបស់ក្រុមហ៊ុន។

លិខិតផ្ទេរសិទ្ធិនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃទី..........ខែ.................ឆ្នាំ

**ប្រធានក្រុមប្រឹក្សាភិបាល និងជាអ្នកប្រគល់សិទ្ធ**
*(ហត្ថលេខា និងត្រា)*

**ក**

បានអាន និងយល់ព្រម
**ទទួលមុខងារជាសវនករ**
*(ហត្ថលេខា)*

**ប**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * *

**ក្រុមហ៊ុន ក.ក.ក ៦.ក**

**KOR.KOR.KOR CO., LTD.**

ធ្វើនៅថ្ងៃទី ខែ ឆ្នាំ

**របាយការណ៍ស្តីពី**
**ការជម្រះបញ្ជី រំលាយក្រុមហ៊ុន កខគ ៦.ក**
**ដើម្បីលុបក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម**

**ក្រុមហ៊ុន ក.ក.ក ៦.ក** គឺជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតស្របតាមច្បាប់ និង បទដ្ឋាននានា នៅក្រសួងពាណិជ្ជកម្មក្រោមបញ្ជី 000000000 ចុះថ្ងៃទី ខែ ឆ្នាំ និងបានចុះបញ្ជីស្ថាពរ នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមលេខ អត្តសញ្ញាណកម្មសារពើពន្ធ (អ.ត.ប) ដែលមានអាសយដ្ឋានចុះបញ្ជីជាគោលដើមនៅ លេខ ០០ ផ្លូវ ០០ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

យោងតាមសេចក្តីសម្រេចនិងសេចក្តីប្រកាសស្តីពីការរំលាយ **ក្រុមហ៊ុន ក.ក.ក ៦.ក**។

យោងតាមលក្ខន្តិកៈ សមាសភាពម្ចាស់ភាគហ៊ុន ៖

- លោក **ក** ជាប្រធានក្រុមប្រឹក្សាភិបាល កាន់កាប់ភាគហ៊ុនចំនួន ៥១០ ភាគហ៊ុន
- លោក **ខ** ជាអភិបាល កាន់កាប់ភាគហ៊ុនចំនួន ៤៩០ ភាគហ៊ុន

ម្ចាស់ភាគហ៊ុនខាងលើកាន់កាប់ភាគហ៊ុន ១០០០ ភាគហ៊ុន ស្មើនឹង ៤០.០០០.០០០ រៀល ដែលក្នុងមួយភាគហ៊ុនតម្លៃ ៤០.០០០ រៀល ដែលភាគហ៊ុននេះត្រូវបង់បញ្ចូលក្នុងក្រុមហ៊ុនទាំងស្រុង និងគ្រប់ចំនួន។

ដោយពុំមានទីផ្សារសមស្រប **ក្រុមហ៊ុន ក.ក.ក ៦.ក** សម្រេចបញ្ឈប់សកម្មភាព អាជីវកម្មរបស់ខ្លួនជាស្ថាពរមុនកាលកំណត់។

ក្រោយប្រកាសរំលាយ អាជីវកម្ម ម្ចាស់ភាគហ៊ុន សម្រេចធ្វើការបែងចែក និងចាត់ចែងទ្រព្យសម្បត្តិ និងទុនដែលនៅសល់ដូចមានក្នុងរបាយការណ៍ ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន គិតត្រឹមតែ ថ្ងៃទី ខែ ឆ្នាំ ទៅតាម សមាមាត្រនៃភាគរយ នៃភាគហ៊ុនដែលមានចែងក្នុងលក្ខន្តិកៈ ដូចខាងក្រោម:

**១. <u>ចំពោះ គណនី ទ្រព្យសកម្មរយៈពេលខ្លី</u> (<u>Current Assets</u>) ៖**

**១.១ ចំពោះគណនីសាច់ប្រាក់នៅក្នុងបេឡានិងនៅធនាគារ** (Cash on hand and in Banks) **(គិតជារៀល)៖**

គណនីសាច់ប្រាក់នៅក្នុងដៃ និងនៅធនាគារ រៀល

**២ <u>បំណុលសារពើពន្ធ ចំពោះរដ្ឋ</u> ៖**

បន្ទាប់ពីបានដាក់លិខិត ស្នើសុំបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ ជូនអគ្គនាយកដ្ឋានពន្ធដាររួចមកក្រុមហ៊ុន បានទទួលការធ្វើសវនកម្មសារពើពន្ធរួចរាល់ និងទទួលបានលិខិតកំណត់ពន្ធឡើងវិញ តាមរយៈលិខិតជូនដំណឹងលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមិនតម្រូវអោយមានការកំណត់ពន្ធឡើងវិញទេ។

ក្រុមហ៊ុនបានធ្វើការទូទាត់រួចរាល់ តាមរយៈបង្កាន់ដៃបង់ពន្ធលេខ                ក្រោយពី បានទូទាត់រួចក្រុមហ៊ុនបានទទួលលិខិតបញ្ជាក់សារពើពន្ធពីអគ្គនាយកដ្ឋានពន្ធដារជាស្ថាពរ។ ការទូទាត់ប្រាក់បំណុលពន្ធនេះ ជាបន្ទុករបស់ម្ចាស់ហ៊ុន ។

**៣. <u>បំណុលសាធារណៈ</u> ៖**

ក្រុមហ៊ុន ពុំមានជំពាក់បំណុល សាធារណៈទេ ឬ បំពុលចំពោះតតីយជន ណាមួយឡើយ ក្នុងអំឡុងពេលចាប់ផ្តើមរហូតដល់បិទអាជីវកម្ម ហើយម្ចាស់ភាគហ៊ុនខាងលើ សូមធានារាល់បំណុលទាំងឡាយ ចំពោះមុខច្បាប់ជាធរមានប្រសិនបើមានភាគីណាមួយចេញមុខបញ្ជាក់ពីបំណុលណាមួយដែលក្រុមហ៊ុនចាប់ពីថ្ងៃរំលាយរហូតដល់រយៈពេល ១០ ឆ្នាំ ខាងមុខ។

ភាគីទាំងអស់បានយល់ព្រម ធ្វើការរំលាយក្រុមហ៊ុន និងបែងចែកទ្រព្យសម្បត្តិដូចបានកំណត់តាមនីតិវិធីខាងលើ ទៅតាមសមាមាត្រ ដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន និងបានចុះហត្ថលេខាទទួលស្គាល់ខាងក្រោម៖

| ក | ខ |
|---|---|
| | |
| ប្រធានក្រុមប្រឹក្សាភិបាល<br>និងជាអ្នកជំរះបញ្ជី | អភិបាល |

| ច | ប្រថាប់ត្រាក្រុមហ៊ុន |
|---|---|
| | |
| សវនករ | |